នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស(អបជ....) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2018, 11:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អ.ប.ជ:**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:** សាធារណៈ/Public

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការចោទសួរ *ដីកាដំណោះស្រាយ(សម្ងាត់ហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ *ដីកាដំណោះស្រាយ(សម្ងាត់ហេតុ)***

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ:**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
**ទាំងអស់នៃសំណុំរឿង០០៤/១**

**សហមេធាវី អ៊ុំ ចែម:**
ប៊ិត ស៊ាងលឹម
Wayne JORDASH

## I. សេចក្តីផ្តើម

1. ដោយអនុលោមតាមវិធាន ៧៣ និង ៧៤ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ (“សពអ”) ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត (សចស) ដែលកោសលុបពីច្បាប់សម្រាប់សាធារណៈនៃ *ដីកាដំណោះស្រាយ(សម្អាងហេតុ)* នៃសំណុំរឿង០០៤/១ នូវសម្អាងហេតុ និងការរកឃើញនានារបស់ សចស ទាក់ទងនឹងអង្គហេតុនៃឧក្រិដ្ឋកម្មជាសារវ័ន្តទាំងឡាយនៅក្នុង*ដីកាដំណោះស្រាយ(សម្អាងហេតុ)*[1] រួមទាំងភស្តុតាងគាំទ្រដែលមាននៅក្នុងនោះ។ សពអ សន្និដ្ឋានថា សចស ខកខានមិនបានផ្តល់ភស្តុតាងបញ្ជាក់ឲ្យបានគ្រប់គ្រាន់នៅក្នុង *“ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សម្អាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ*[2] (“ដីកាសម្រេចដែលរងការជំទាស់”) ឬ បើផ្សេងពីនេះ មូលហេតុអ្វីបានជាចំណាប់អារម្មណ៍របស់សាធារណជនដ៏ខ្លាំងក្លា នៅក្នុងលទ្ធភាពចូលពិនិត្យមើលសម្អាងហេតុពេញលេញនៃ *ដីកាដំណោះស្រាយ(សម្អាងហេតុ)* ត្រូវបានលុបបំបាត់ទៅវិញនៅក្នុងតួយ៉ាងនេះ និងគ្មានមូលហេតុដែលគួរឲ្យជឿជាក់បានទៀតផង។

2. តាមជម្រើសផ្សេង អនុលោមតាមមាត្រា៩ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសំណុំរឿង និង មាត្រា ៣.១២ និង ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក សពអ សូមស្នើឲ្យអង្គបុរេជំនុំជម្រះ (អបជ) ប្រើសិទ្ធិអំណាចរបស់ខ្លួន ខណៈដែលអង្គជំនុំជម្រះនេះត្រូវបានប្តឹងឲ្យទទួលយកសំណុំរឿង០០៤/១ ដើម្បីធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះ *ដីកាដំណោះស្រាយ(សម្អាងហេតុ)* បច្ចុប្បន្នដែលដាក់ថាសម្ងាត់ ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ លើកលែងតែការកោសលុបណាដែលចាំបាច់ ស្របតាមវិធាន២៩ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងវិធានការការពារសម្រាប់ជនរងគ្រោះ និងសាក្សីប៉ុណ្ណោះ។ សចស ក៏សូមស្នើឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញទៅជាសាធារណៈផងដែរ ចំពោះដីកាសម្រេចដែលរងការជំទាស់។

## II. ប្រវត្តិនីតិវិធី

---

[1] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) — សាធារណៈ (កោសលុប), ១០ កក្កដា ២០១៧។

[2] **D309/2** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ, ១០ កក្កដា ២០១៧ (ចាប់ពីនេះតទៅហៅថា “ដីកាសម្រេចដែលរងការជំទាស់”)។

3. ដីកាសន្និដ្ឋានដំបូងសម្រាប់សំណុំរឿង០០៤ ដែលបានកំណត់ឈ្មោះ អ៊ឹម ចែម ថាជាជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យបួននាក់ ត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្តីទី នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។ ជាងប្រាំបីឆ្នាំក្រោយមក គឺនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ សចស បានចេញ*ដីកាដំណោះស្រាយ(ផ្នែកសម្រេចសេចក្តី)* ដោយសម្រេចថា អ៊ឹម ចែម មិនស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទេ ហើយបានលើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់[3]។ ពួកគាត់និយាយថា“សម្អាងហេតុពេញលេញសម្រាប់ការសន្និដ្ឋាននេះ” នឹងផ្តល់ជូននៅក្នុងការដាក់ឯកសារដាច់ដោយឡែកមួយ[4]។

4. នៅថ្ងៃដដែល សចស បានចេញសេចក្តីប្រកាសព័ត៌មានមួយដោយប្រកាសថា ការលើកលែងការចោទប្រកាន់ ដែលបានថ្លែងបញ្ជាក់មួយផ្នែកថា៖ “ដោយសារថា ដីកាដំណោះស្រាយមានលក្ខណៈជាការលើកលែងការចោទប្រកាន់ សម្អាងហេតុសម្រាប់សេចក្តីសម្រេចនេះ ដោយសារវាពាក់ព័ន្ធរហូតដល់ខ្លឹមសារនៃបទចោទ ហើយនឹងដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវរក្សាទុកជាការសម្ងាត់ រហូតដល់អង្គបុរេជំនុំជម្រះសម្រេចបដិសេធលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ”[5]។

5. នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ សពអ បានដាក់សំណើមួយដោយស្នើឱ្យដាក់ *ដីកាដំណោះស្រាយ(សម្អាងហេតុ)* ជាសាធារណៈនៅពេលចេញ ដោយបានធ្វើការកត់សំគាល់នៅត្រង់ការអះអាងនៅក្នុងសេចក្តីប្រកាសព័ត៌មានថា ការផ្តល់សម្អាងហេតុនៃដីកាសម្រេចទាក់ទងនឹងខ្លឹមសារនៃបទចោទនៅតែរក្សាជាការសម្ងាត់[6]។ សពអ សង្កេតឃើញថា គ្មានវិធានណាមួយឱ្យដឹងថា ដីកាដំណោះ

---

3 **D308** ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី), ២២ កុម្ភៈ ២០១៧។

4 **D308** ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី), ២២ កុម្ភៈ ២០១៧, កថាខណ្ឌ ១២។

5 សេចក្តីប្រកាសព័ត៌មាន ដោយសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ២២ កុម្ភៈ ២០១៧។

6 **D309** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ សចស ត្រូវធ្វើឡើងជាសាធារណៈ, ៧ មីនា ២០១៧។

01527358



ស្រាយ ទោះជាចោទ ឬលើកលែងការចោទប្រកាន់ក៏ដោយ ត្រូវរក្សាជាការសម្ងាត់នោះទេ[7]។ គាត់ក៏បានកត់សំគាល់ផងដែរថា យុត្តិសាស្ត្រអន្តរជាតិអនុគ្រោះចំពោះកិច្ចដំណើរការនីតិវិធីតុលាការ[8]។

6. នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ អ៊ឹម ចែម បានឆ្លើយតប ដោយតវ៉ាថា សំណើសុំរបស់ សពអ ទាក់ទងនឹង *ដីកាដំណោះស្រាយ(សម្អាងហេតុ)* គឺជាការឆាប់ពេក[9]។

7. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សចស បានចេញ *ដីកាដំណោះស្រាយ(សម្អាងហេតុ)* ទាំងពីរទម្រង់ជាសាធារណៈផង និងសម្ងាត់ផង[10]។ ច្បាប់កោសលុបសម្រាប់សាធារណៈ បានកោសលុបសឹងតែពាក់កណ្ដាលនៃ*ដីកាដំណោះស្រាយ(សម្អាងហេតុ)* រួមទាំងការវាយតម្លៃបទឧក្រិដ្ឋសំខាន់ៗទាំងអស់។ សំណៅសម្រាប់សាធារណៈនេះក៏បានកោសលុបសេចក្ដីយោងនានាទៅរកកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងអស់ផងដែរ រួមទាំងកំណត់ហេតុនៃការស្ដាប់ចម្លើយ ដែលបានផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណីផង[11]។

8. នៅថ្ងៃដដែល សចស បានចេញដីកាសម្រេចដែលរងការជំទាស់ ដោយបដិសេធសំណើសុំឲ្យដាក់*ដីកាដំណោះស្រាយ(សម្អាងហេតុ)*ជាសាធារណៈពេញលេញ[12] ដោយសម្រេចថា ការសម្រេចនេះគឺស្ថិតក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន និងថាពួកគាត់បានថ្លែងពីមុនថា សម្អាងហេតុទាក់ទងនឹងខ្លឹមសារនៃបទចោទ នៅតែរក្សាជាការសម្ងាត់ដដែល ហើយបើដូច្នេះ ពួកគាត់នៅតែប្រកាន់យកតាមសេចក្ដីសម្រេចពីមុនរបស់ខ្លួនដដែល[13]។

---

7 **D309** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ សចស ត្រូវធ្វើឡើងជាសាធារណៈ, ៧ មីនា ២០១៧, កថាខណ្ឌ ៣។

8 **D309** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ សចស ត្រូវធ្វើឡើងជាសាធារណៈ, ៧ មីនា ២០១៧, កថាខណ្ឌ ៧, ៨។

9 **D309/1** ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសំណើរបសសហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សេចក្តីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ (D309), ២០ មីនា ២០១៧។

10 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧។

11 *សូមអាន ជាឧទាហរណ៍* **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កំណត់សំគាល់ជើងទំព័រ ៣៣, ៣៣៤, ៣៤២។

12 **D309/2** ដីកាសម្រេចដែលរងការជំទាស់។

13 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៤។

9. នៅថ្ងៃ១០ ខែកក្កដា ឆ្នាំ២០១៧ នេះដែរ សចស បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយបានថ្លែងថា៖

> ដោយសារមានការលើកលែងការចោទប្រកាន់ដោយមូលហេតុថា មិនមានយុត្តាធិការគ្រប់គ្រាន់នោះ ទើប អ៊ឹម ចែម នៅតែបន្តមានសិទ្ធិទទួលបានការសន្មតថាគ្មានទោស និងសិទ្ធិឯកជនរបស់គាត់ ដែលបណ្តាលឲ្យមានការរឹតត្បិត នូវព័ត៌មានមួយចំនួនដែលអាចផ្សព្វផ្សាយជាសាធារណៈ ហើយការរឹតត្បិតនេះមានលក្ខណៈតឹងរ៉ឹងជាងករណីដែលបញ្ជូនគាត់ទៅជំនុំជម្រះ។ សិទ្ធិទាំងនេះអនុវត្តបានមែន ប៉ុន្តែ នៅតែអាចបើកផ្លូវឲ្យសាធារណជនទទួលបាននូវព័ត៌មានគ្រប់គ្រាន់អំពីការវិវត្តនៃកិច្ចដំណើរការនីតិវិធី[14]។

10. នៅថ្ងៃ១៣ ខែកក្កដា ឆ្នាំ២០១៧ សពអ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[15]។

11. នៅថ្ងៃ៣ ខែសីហា ឆ្នាំ២០១៧ សពអ បានដាក់សំណើមួយសុំដាក់បណ្តឹងឧទ្ធរណ៍របស់គាត់ តែមួយភាសាអង់គ្លេស ចំណែកសំណៅបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន[16]។

## III. ច្បាប់ជាធរមាន

12. វិធាន ២១ នៃវិធានផ្ទៃក្នុងស្តីពី “គោលការណ៍ជាមូលដ្ឋាន” ចែងនៅក្នុងផ្នែកពាក់ព័ន្ធ ថា៖

---

[14] សេចក្តីប្រកាសព័ត៌មាន ដោយសហចៅក្រមស៊ើបអង្កេត ចេញសំអាងហេតុលើកលែងការចោទប្រកាន់សំណុំរឿង ០០៤/១, ១០ កក្កដា ២០១៧។

[15] **D309/2/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំសំអាងហេតុនៃដីកាដំណោះស្រាយធ្វើអោយទៅជាសាធារណៈ, ១៣ កក្កដា ២០១៧។

[16] **D309/2/1/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ដើម្បីកោសលុប*ដីកាដំណោះស្រាយ (សំអាងហេតុ)* ជាភាសាអង់គ្លេសជាមុនសិន ចំណែកច្បាប់បកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ, ៣ សីហា ២០១៧។

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ជាធរមានទាំងអស់ ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ **ដើម្បីធានា**អំពីសច្ចភាពផ្លូវច្បាប់ និង**កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព** ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងនៅក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ ៖

----

គ) អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា **ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន** ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី”[17](សង្កត់ន័យត្រង់ឃ្លាអក្សរដិតធំ)។

13. វិធាន ៥៦ នៃវិធានផ្ទៃក្នុងស្តីពី “ការផ្តល់ព័ត៌មានដល់សាធារណជន ដោយសហចៅក្រមស៊ើបអង្កេត” ចែងនៅក្នុងផ្នែកពាក់ព័ន្ធ ថា៖

១. ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី កិច្ចស៊ើបសួរមិន**ត្រូវធ្វើឡើង**ជាសាធារណៈឡើយ។ .... ”[18] (សង្កត់ន័យត្រង់ឃ្លាអក្សរដិតធំ)។

## IV. **អំណះអំណាង**

14. មានការចាប់អារម្មណ៍ពីសាធារណជនយ៉ាងខ្លាំង ក្នុងការទទួលបានលទ្ធភាពចូលពិនិត្យមើល *ដីកាដំណោះស្រាយ(សម្លាងហេតុ)* ក្នុងសំណុំរឿង០០៤/១។ នេះជាឯកសារដែលមានការពាក់ព័ន្ធនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នង ដែលបានធ្វើឱ្យប៉ះពាល់ហោចណាស់ដល់មនុស្សរាប់ម៉ឺននាក់។ ក្នុងវាក្យខណ្ឌដែលពេលនេះសាធារណជនមិនអាចចូលពិនិត្យមើលបាន *ដីកាដំណោះស្រាយ(សម្លាងហេតុ)* រៀបរាប់អំពីភ័ស្តុតាងដែលបានស្រាវជ្រាវរកឃើញនៅក្នុងកិច្ចស៊ើបសួរដែលប្រើពេលជាច្រើនឆ្នាំ ស្មុគស្មាញនិងយ៉ាងត្រឹមត្រូវនោះ វាបានពន្យល់ពីរបៀបដែល សចស

---

17 វិធាន ២១ នៃវិធានផ្ទៃក្នុង (សង្កត់ន័យដើម)។

18 វិធាន ៥៦ នៃវិធានផ្ទៃក្នុង (សង្កត់ន័យដើម)។

បានពិចារណាថា ភ័ស្តុតាងដែលបានធ្វើឲ្យប៉ះពាល់ដល់សេចក្តីសម្រេចរបស់ពួកគាត់ ដែលថា អ៊ឹម ចែម មិនមែនជាបុគ្គលម្នាក់នៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម តាមការពិភាក្សាពីទម្ងន់នៃបទឧក្រិដ្ឋ និងអំពីថាតើភ័ស្តុតាងបង្ហាញឲ្យឃើញពីតំណភ្ជាប់ណាមួយដែលអាចគាំទ្រដល់ការបញ្ជូនខ្លួន អ៊ឹម ចែម ទៅជំនុំជម្រះតាមការចោទគាត់ ចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំនោះដែរឬអត់។

15. ដោយសារសំណៅសម្រាប់សាធារណជននៃឯកសារនេះ ត្រូវបានកោសលុបយ៉ាងច្រើន ដើម្បីដកចេញនូវកិច្ចពិភាក្សាទាំងអស់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម នោះ ជនរងគ្រោះ និងសមាជិកគ្រួសារដែលរស់រានមានជីវិតរបស់ពួកគាត់ ដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/១ ពុំមានសិទ្ធិចូលពិនិត្យមើលការរកឃើញផ្នែកអង្គហេតុ និងអង្គច្បាប់ដោយ សចស ឡើយ ទោះបីការពិត មាត្រា ២១ ផ្តល់អាណត្តិឲ្យជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ក៏ដោយ។ ជាការបន្ថែម សាធារណជនទូទៅនៅកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងភាគីដែលពាក់ព័ន្ធនៅក្នុងសហគមន៍ជាតិ និងអន្តរជាតិ ក៏ត្រូវបានទុកចោលក្នុងភាពងងឹតទាំងស្រុងដែរ ដោយសារតែការរកឃើញរបស់ សចស ចំពោះបញ្ហាទាំងនេះ។

16. មិនត្រឹមតែបុគ្គល ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីឧក្រិដ្ឋកម្មខ្មែរក្រហមប៉ុណ្ណោះទេ សូម្បីតែសហគមន៍អន្តរជាតិទាំងមូល ក៏មានចំណាប់អារម្មណ៍ចង់ដឹងពីសម្អាងហេតុពេញលេញនៃ *ដីកាដំណោះស្រាយ(សម្អាងហេតុ)* ដែរ។ ដូចអង្គជំនុំជម្រះនេះបានដឹងយ៉ាងច្បាស់ហើយថា អ.វ.ត.ក ខ្លួនឯងផ្ទាល់ បានកើតឡើងតាមរយៈការខិតខំខ្នះខ្នែងរួមគ្នារវាងសហគមន៍អន្តរជាតិ (តាមរយៈអង្គការសហប្រជាជាតិ) និងរាជរដ្ឋាភិបាលកម្ពុជា។ មហាសន្និបាតសហប្រជាជាតិបានធ្វើការកត់សំគាល់ថា“ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជានិងអន្តរជាតិ ក្នុងអំឡុងពេលនៃសម័យកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់១៩៧៩ នៅតែបន្តជាកង្វល់ដ៏សំខាន់ចំពោះសហគមន៍អន្តរជាតិទាំងមូល”[19]។ សារៈសំខាន់នៃតម្លាភាពរបស់តុលាការជាទូទៅ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ/មានលក្ខណៈជាអន្តរជាតិ រួមទាំង អ.វ.ត.ក បង្កើតបានជាពិសេសនូវអាជ្ញាបញ្ញាធម្មនិយាមនៃលទ្ធភាពរបស់សាធារណជនយ៉ាងពេញលេញ។

---

[19] ដំណោះស្រាយដែលបានអនុមតិដោយមហាសន្និបាត, 57/228 ការជំនុំជម្រះក្តីខ្មែរក្រហម, ២៧ កុម្ភៈ ២០០៣, ទំព័រ១។

17. ការកោសលុបយ៉ាងច្រើនសន្ធឹកសន្ធាប់ពីសំណៅជាសាធារណៈ ស្ទើរតែបង្កឱ្យមានការយល់ច្រឡំពីសាធារណជនចំពោះការរកឃើញ និងការសន្និដ្ឋានរបស់ សចស ទៅហើយ។ ឧទាហរណ៍ ខណៈដែល សចស រកឃើញភ័ស្តុតាងដ៏សំខាន់អំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរជាច្រើននោះ មេធាវីរបស់ អ៊ឹម ចែម ក៏បានចេញសេចក្តីប្រកាសព័ត៌មានមួយដោយអះអាងថា "សេចក្តីសម្រេចនាថ្ងៃនេះ គឺជាជំហាដ៏មានសារសំខាន់មួយ ឆ្ពោះទៅរកការបង្ហាញឱ្យឃើញពីនិរទោសរបស់គាត់ [អ៊ឹម ចែម] និងភាពជ្រះស្រឡះរបស់គាត់"[20]។ ខណៈដែល សពអ យល់ស្របថា វាតែងតែជាការសំខាន់ដើម្បីរំលឹកសាធារណជនថា អ៊ឹម ចែម ដូចជនសង្ស័យ ឬជនជាប់ចោទទាំងអស់ដែរ មានសិទ្ធិទទួលបានសច្ចធារណ៍នៃនិរទោស វៀរលែងតែ និងរហូតដល់ពេលពិរុទ្ធភាពរបស់គាត់ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យនៅក្នុងសវនាការក៏ដោយ ក៏វានឹងធ្វើឱ្យសាធារណជនយល់ច្រឡំដែលនិយាយថា *ដំណោះស្រាយ(សម្អាងហេតុ)* របស់ សចស បង្ហាញឱ្យឃើញថា គាត់គឺជា "ជនស្លូតត្រង់" ដែលតាមការពិត សចស បានរកឃើញថា អ៊ឹម ចែម បានរួមចំណែកតាមមធ្យោបាយជាច្រើនដល់ឧក្រិដ្ឋកម្មដ៏សែនធ្ងន់ធ្ងរទាំងនោះ។

18. អ្នកតាមដាន និងអ្នកសង្កេតការណ៍តុលាការ បានរិះគន់ចំពោះការកោសលុបដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុង *ដីកាដំណោះស្រាយ(សម្អាងហេតុ)* ដោយពួកគាត់ថ្លែងថា "សេចក្តីសម្រេចជាសាធារណៈនេះបង្ហាញឱ្យឃើញពីបរាជ័យខាងស្មារតីនៃតម្លាភាព ដែលមានសារៈសំខាន់ដល់ដំណើរការជាសាធារណៈដែលគួរឱ្យជឿជាក់បាន"[21] និង "ជាការគួរឱ្យសោកស្តាយ ដែលសម្អាងហេតុសំខាន់ៗនៃដីកាសម្រេច[របស់សហចៅក្រមស៊ើបអង្កេត] ហាក់ដូចជាលាក់បង្កប់អ្វីម្យ៉ាងនៅពីក្រោយបន្ទះដ៏ធំមួយ ដែលនឹងបញ្ឆោះឱ្យមានតែការសន្និដ្ឋានស្មានៗ និងមន្ទិលប៉ុណ្ណោះ ថាហេតុអ្វីបានជាសំណុំរឿងនេះត្រូវបានលើកលែងការចោទប្រកាន់"[22]។

## ក. ច្បាប់ជាធរមាន និងគោលការណ៍តម្រូវឱ្យមាន*ដីកាដំណោះស្រាយ(សម្អាងហេតុ)* ទាំងស្រុងត្រូវដាក់ជាសាធារណៈ

[20] *អ៊ឹម ចែម សរសើរសេចក្តីសម្រេច,* Phnom Penh Post, ១៣ កក្កដា ២០១៧។

[21] *សេចក្តីសម្រេចដែលបានកែតម្រូវរបស់សាលាក្តី ស្តីពី អ៊ឹម ចែម បង្កឱ្យមានកំហឹង*, Phnom Penh Post, ១២ កក្កដា ២០១៧ (ដកស្រង់ Heather Ryan, អង្គការ Open Society Justice Initiative)។

[22] *សេចក្តីសម្រេចដែលបានកែតម្រូវរបស់សាលាក្តី ស្តីពី អ៊ឹម ចែម បង្កឱ្យមានកំហឹង*, Phnom Penh Post, ១២ កក្កដា ២០១៧ (ដកស្រង់ John Ciorciari, សកលវិទ្យាល័យមីឈីហ្គិន (University of Michigan))។

19. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សចស "រំឭកភាគីទាំងអស់ថា កម្រិតតម្លាភាពដែលត្រូវការជាចាំបាច់ត្រូវបានកំណត់រួចហើយនៅក្នុងច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង ច្បាប់បន្ថែមផ្សេងទៀតរបស់ប្រទេសកម្ពុជា និងវិធានច្បាប់អន្តរជាតិជាធរមាន"[23]។ សពអ យល់ព្រមទាំងស្រុងថា ប្រភពទាំងនេះពិតជាបានដាក់បញ្ញត្តិឱ្យមានតម្លាភាពចាំបាច់ ដើម្បីធានាដល់សេចក្ដីទុកចិត្តរបស់សាធារណជននៅក្នុងដំណើរការនីតិវិធី។ យ៉ាងណាក៏ដោយ ចំពោះមូលហេតុដូចបានពន្យល់នៅខាងក្រោម គាត់បានសន្និដ្ឋានថា ប្រភពទាំងនេះគាំទ្រដល់ការចូលមើលបានជាសាធារណៈនូវ *ដីកាដំណោះស្រាយ(សម្អាងហេតុ)* ទាំងស្រុងនេះ។

*i. ច្បាប់ អ.វ.ត.ក, វិធាន, និង ករណីយុត្តិសាស្ត្រ មានទំនោរទៅរកតម្លាភាព*

20. អាណត្តិដ៏លើសលុបនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក - យ៉ាងជាក់ស្ដែងនៅក្នុងកិច្ចព្រមព្រៀង វិធាន សេចក្ដីណែនាំអនុវត្តន៍ និងករណីយុត្តិសាស្ត្រ - ជាពិសេស វិធាន២១ គឺមានតម្លាភាពជាអតិបរមា ត្រូវគ្នាទៅនឹងការប្រព្រឹត្តិទៅដ៏ត្រឹមត្រូវនៃតុលាការ។ វិធាន៥៦ បានចែងពីការលើកលែងដែលមានកម្រិត និងសមហេតុផល ទៅនឹងគោលការណ៍ដ៏លើសលុបនេះ តាមរយៈការដាក់អាណត្តិថា ក្នុងកំឡុងពេលនៃកិច្ចស៊ើបសួរត្រូវបាន**កំពុងដំណើរការ** បទដ្ឋានត្រូវរក្សាបាននូវការសម្ងាត់។ ការសម្ងាត់ជួយធានាឱ្យសាក្សីនានាមិនត្រូវបានជះឥទ្ធិពលលើដោយសក្ដីកម្មរបស់អ្នកដទៃ និងបម្រើឱ្យ "ការពារសុចរិតភាពនៃកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការ និងត្រូវធានាសន្តិសុខរបស់សាក្សីទាំងនោះ"[24]។ យ៉ាងណាក៏ដោយ សូម្បីតែនៅក្នុងកំឡុងពេលនៃដំណើរការស៊ើបសួរជាសម្ងាត់ អាណត្តិសម្រាប់ការចូលមើលជាសាធារណៈនៅរក្សាជំហរបានជាដដែល។ វិធានបានអនុញ្ញាតជាពិសេសដល់ សចស និង អបជ ឱ្យចាត់ប្រភេទឯកសារឡើងវិញ។ បន្ថែមលើនេះ វិធានបានចែងពីកាលានុវត្តភាពសម្រាប់សហព្រះរាជអាជ្ញា និង សចស រក្សាឱ្យបានថា សាធារណជនបានដឹងពីព័ត៌មាន ក្នុងកំឡុងពេលនៃដំណើរការនៃការស៊ើបសួរ តាមរយៈសេចក្ដីថ្លែងការណ៍ជាសាធារណៈ។

---

23 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ១៥។

24 **D193/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញកំណត់ហេតុស្ដាប់ចម្លើយ សំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/២, ៨ ឧសភា ២០១៤, កថាខណ្ឌ៩។

21. យ៉ាងណាក៏ដោយ កាលណាកិច្ចស៊ើបសួរត្រូវបានបញ្ចប់ហើយនោះ ការសម្ងាត់ដែលបានតម្រូវដោយខចែងជាក់លាក់នៃវិធាន៥៦ ខណៈដែលកិច្ចស៊ើបសួរកំពុងត្រូវបានដំណើរការនោះ លែងអនុវត្តទៀតហើយ។ វិធាន៦៦ បានរៀបរាប់នូវជំហានផ្សេងៗនៃកិច្ចដំណើរការនីតិវិធីដែលត្រូវកើតឡើង នៅក្រោយការបិទកិច្ចស៊ើបសួរ។ តាមរយៈខចែងនៃវិធាន៦៦(៥) គឺវាច្បាស់លាស់ហើយដែលថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ជូនតែកាលណា "សហព្រះរាជអាជ្ញា យល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា ការស៊ើបសួរត្រូវបានចប់សព្វគ្រប់ហើយ"[25]។ ដូច្នេះ គឺវាច្បាស់លាស់ពីវិធានផ្ទៃក្នុងហើយដែលថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចម្លើយតបណាមួយពីមេធាវីការពារក្ដី និងដីកាដំណោះស្រាយរបស់ សចស អាចត្រូវបានដាក់ តែនៅក្រោយរយៈពេលដែលកិច្ចស៊ើបសួរត្រូវបាន "ដំណើរការ" ប៉ុណ្ណោះ។ អាស្រ័យហេតុដូច្នេះ លក្ខខណ្ឌតម្រូវនៃវិធាន៥៥ ដែលថាកិច្ចស៊ើបសួរមិនត្រូវបានដំណើរការជាសាធារណៈ គឺមិនអាចអនុវត្តបានចំពោះឯកសារទាំងនេះ។

22. អ.វ.ត.ក បានចងក្រងជារចនាសម្ព័ន្ធប្រយោជន៍ដើម្បីថា ដរាបណាភាពចាំបាច់នៃកិច្ចស៊ើបសួរជាសម្ងាត់ត្រូវបានរាប់បញ្ចូលនោះ កិច្ចដំណើរការនីតិវិធីរបស់តុលាការនេះនឹងត្រឡប់ទៅរក *ស្ថានភាពឥតផ្លាស់ប្ដូរ status quo* នៃការបើកចូលមើលជាសាធារណៈបានជាអតិបរមា។ ចំពោះមូលហេតុនេះ កិច្ចព្រមព្រៀង វិធាន និងសេចក្ដីណែនាំអនុវត្ត បានចែងយ៉ាងច្បាស់លាស់ថាជាមួយនឹងការលើកលែងដ៏តូចមួយ រាល់ដីកាសម្រេចទាំងអស់របស់ អបជ គឺជាសាធារណៈ ថារាល់កិច្ចដំណើរការនិតិវិធីសវនាការទាំងអស់គឺត្រូវកើតឡើងជាសាធារណៈ ថាសាលក្រមត្រូវបានចេញជាសាធារណៈ ថាកិច្ចដំណើរការនិតិវិធីបណ្ដឹងឧទ្ធរណ៍ គឺត្រូវកើតឡើងជាសាធារណៈ ថាសាលដីកាត្រូវបានចេញជាសាធារណៈ និងនៅពេលបញ្ចប់សំណុំរឿងនីមួយៗ ឯកសារសម្ងាត់ដែលនៅសេសសល់គឺត្រូវបានពិនិត្យឡើងវិញសម្រាប់ចំណាត់ថ្នាក់សារជាថ្មីជាសាធារណៈ។

23. តម្លាភាពនៃកិច្ចដំណើរការនិតិវិធី គឺគ្មានវិធីណាមួយនោះឡើយដែលត្រូវគ្នាទៅនឹងសច្ចធារណ៍នៃនិរទោស។ ការជំនុំជម្រះក្ដីត្រូវបានប្រព្រឹត្តទៅជាសាធារណៈ ទោះបីជាជនជាប់ចោទត្រូវបានសន្មតថាគ្មានទោសពេញមួយដំណើរការនៃការជំនុំជម្រះក្ដីក៏ដោយ។ វិធានផ្ទៃក្នុង គឺច្បាស់លាស់

[25] វិធាន៦៦(៥) នៃវិធានផ្ទៃក្នុង។

នឹងត្រូវគ្នាទៅតាមការអនុវត្តជាអន្តរជាតិ ដែលថារាល់សាលក្រមទាំងអស់ត្រូវតែជាសាធារណៈ - សូម្បីតែការដោះលែងជនជាប់ចោទណាម្នាក់ពីរាល់ការចោទប្រកាន់ទាំងអស់ក៏ដោយ ឬបើមិនដូច្នោះទេ ត្រូវលើកលែងការចោទប្រកាន់នោះចោល។ នៅក្នុងស្ថានភាពបែបដូច្នោះ សាធារណជននៅតែមានសិទ្ធិបានដឹងពីមូលដ្ឋានសម្រាប់ការដោះលែងនោះ និងការរកឃើញនូវអង្គហេតុ រួមទាំងអង្គហេតុដែលអវិជ្ជមានចំពោះជនជាប់ចោទដែលត្រូវបានដោះលែងនោះទៀតផងដែរ។ ពិតមែនហើយ នៅពេលដែលមានការនិយាយអំពីការកាត់ឲ្យជាប់ទោស ឬការដោះលែងនោះ ទំនុកចិត្តរបស់សាធារណជននៅក្នុងសច្ចភាពនៃដំណើរការយុត្តិធម៌ វាអាស្រ័យលើតម្លាភាពនៅក្នុងសេចក្តីសម្រេចបែបដូច្នោះ។ ការស៊ើបសួរនៅក្នុងសំណុំរឿង០០៤/១ បានបញ្ចប់ទៅហើយ ដែលរាល់សកម្មភាពបន្ថែមទៀត - រួមមាន ការចេញ*ដីកាដំណោះស្រាយ(សម្លាងហេតុ)* - ដោយ សចស, ត្រូវតែបានកើតឡើងនៅក្រោមបទដ្ឋាននៃ*ស្ថានភាពឥតផ្លាស់ប្តូរ status quo:* ការបើកចូលមើលជាសាធារណៈបានជាអតិបរមា មិនមែនមានវិសមិតភាពទៅនឹងដំណើរការដ៏ត្រឹមត្រូវនៃតុលាការនោះទេ។

24. សេចក្តីណែនាំនៃតម្លាភាពដែលអាចធ្វើបានជាអតិបរមានៅ អ.វ.ត.ក អាចត្រូវបានឃើញនៅក្នុងមាត្រា១២(២) នៃកិច្ចព្រមព្រៀង ដែលបានដាក់បញ្ចូលនៅក្នុងមាត្រា១៤ នៃសន្ធិសញ្ញា ICCPR និងបានបញ្ជាក់ពីការចាំបាច់ និងបំណងសម្រាប់ការបើកចូលមើលជាសាធារណៈបានទៅនឹង "កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ" ដោយមានការលើកលែងដែលមានកម្រិត។ ខណៈដែលវិធាននៃផ្ទៃក្នុងរបស់ អ.វ.ត.ក មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ទេថា តើពេលណាដែលដីកាដំណោះស្រាយត្រូវចេញជាសាធារណៈ[26] ឬមួយពេលណាដែលពួកវាត្រូវហាមឃាត់។ ហើយវិធាននៃផ្ទៃក្នុងនេះទាំងមូល បានបញ្ជាក់ពីការចូលចិត្តយ៉ាងខ្លាំងទៅលើតម្លាភាព ជាពិសេសគឺនៅពេលដែលកិច្ចស៊ើបសួរត្រូវបានបញ្ចប់។

25. វិធាន២១ ចែងជាផ្នែកនៃ "បទប្បញ្ញត្តិទូទៅ" ថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយ...ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង**កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព**."[27]។

[26] វិធាន៦៧ នៃវិធានផ្ទៃក្នុង ស្តីពី "ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត" នៅស្ងៀមស្ងាត់ពីបញ្ហានេះ។

[27] វិធាន២១ នៃវិធានផ្ទៃក្នុង (សង្កត់ន័យបន្ថែមដោយ**អក្សរដិតក្រាស់**)។

វិធាន២១ ក៏បានចែងផងដែរពីបទប្បញ្ញត្តិទូទៅដែលថាក្នុងចំណោមអ្នកដែលផលប្រយោជន៍របស់ខ្លួនត្រូវតែដឹកនាំលើការបកស្រាយវិធាននោះ គឺជាជនរងគ្រោះ និងបានចែងថា "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវ**ទទួលបានការជូនព័ត៌មាន** ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីរឿងក្តី"[28]។ វិធានអនុវត្តចំពោះ"ជនរងគ្រោះ" និងមិនគ្រាន់តែជាភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលជាអនុក្រុមដ៏តូចមួយនៃអ្នកដែលជាជនរងគ្រោះនោះទេ[29]។ យ៉ាងណាក៏ដោយ ដោយសារតែ*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ដែលមិនកោសលុបនេះនៅតែត្រូវបានចាត់ថ្នាក់ជាសម្ងាត់នៅឡើយនោះ គឺមានតែជនរងគ្រោះដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទេដែលអាចបើកចូលមើលបាន។ អាស្រ័យហេតុដូច្នេះ មានជនរងគ្រោះជាច្រើន ដែលមិនត្រូវបានរក្សាឲ្យបានដឹង ដូចដែលបានតម្រូវដោយវិធាន២១ ទេ។

26. ផ្នែកដទៃទៀតនៃវិធានផ្ទៃក្នុងបានបកស្រាយពីចេតនា ក្នុងការរក្សាឲ្យសាធារណជនបានដឹងអំពីការលើកឡើងចោទប្រកាន់ពីអង្គហេតុ និងភស្តុតាង ទៅដល់វិសាលភាពដែលការណ៍នេះអាចត្រូវបានធ្វើឡើង ដោយមិនមានការព្រមព្រៀងទៅដល់សច្ចភាពនៃកិច្ចស៊ើបសួរ ឬការធ្វើឲ្យមានគ្រោះថ្នាក់ដល់សាក្សី។ វិធាន៥៤ ចែងថា សូម្បីតែនៅក្នុងកំឡុងពេលនៃការបំពេញកិច្ចស៊ើបសួរ, "ដោយគិតដល់តម្រូវការក្នុងការផ្តល់ព័ត៌មានដល់សាធារណជន អំពីវិវឌ្ឍនភាពនៃ[កិច្ច]ដំណើរការ[នីតិវិធី]របស់អង្គជំនុំជម្រះវិសាមញ្ញ"[30] សហព្រះរាជអាជ្ញាមានសិទ្ធិដើម្បីផ្តល់ដល់សាធារណជននូវសេចក្តីសង្ខេបនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ។ វិធាន៥៦ ចែងថា សចស ត្រូវបានអនុញ្ញាតឲ្យ "ផ្តល់[]នូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឲ្យសាធារណជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬដើម្បីកែតម្រូវព័ត៌មាន

---

[28] វិធាន២១ នៃវិធានផ្ទៃក្នុង (សង្កត់ន័យបន្ថែមដោយ**អក្សរដិតក្រាស់**)។

[29] ជនរងគ្រោះមិនមែនជាសហាវិបុលកាលជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ *សូមអាន* វិធាន២៣ នៃវិធានផ្ទៃក្នុង (ជនរងគ្រោះអាចដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី)។ វិធានគឺច្បាស់លាស់ថា ជនរងគ្រោះគឺជាបុគ្គលណាក៏ដោយដែល "ទទួលរងគ្រោះថ្នាក់ដោយសារការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក"។ វិធានផ្ទៃក្នុង, ទំព័រ៨៥។ ដើមបណ្តឹងរដ្ឋប្បវេណី គឺជា "ជនរងគ្រោះដែលពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ត្រូវបានប្រកាសថាអាចទទួលយកបាន ដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធានទាំងនេះ [វិធានផ្ទៃក្នុង]"។ វិធានផ្ទៃក្នុង, ទំព័រ ៨៣។

[30] វិធាន៥៤ នៃវិធានផ្ទៃក្នុង។

មិនពិត ឬព័ត៌មាននាំឲ្យមានការភ័ន្តច្រឡំ"។ វានឹងមិនស៊ីគ្នានោះទេ បើសិនជាវិធានបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាជម្រាបព័ត៌មានដល់សាធារណជនអំពីការលើកឡើងចោទប្រកាន់ពីអង្គហេតុប្រឆាំងនឹងជនសង្ស័យណាម្នាក់ដែលពួកគាត់បានប្ដឹងឲ្យ សចស ធ្វើការស៊ើបអង្កេត ប៉ុន្តែមានចេតនាថា សចស មិនជម្រាបប្រាប់ព័ត៌មានដល់សាធារណជនពីដំណោះស្រាយនៃកិច្ចស៊ើបសួររបស់ខ្លួនចូលទៅក្នុងអង្គហេតុទាំងនោះ នៅក្រោយកិច្ចស៊ើបសួរត្រូវបានបញ្ចប់។

27. បន្ថែមលើនេះ ភស្តុតាងស្ដីពីចេតនារបស់អ្នកព្រាងវិធានផ្ទៃក្នុង ដើម្បីធានាពីតម្លាភាពនៅក្នុងបញ្ហានានានៃការស៊ើបអង្កេត និងសេចក្ដីសម្រេចចោទប្រកាន់ លើកលែងតែនៅពេលភាពសម្ងាត់វាចាំបាច់ដើម្បីធានាសច្ចភាពនៃការធ្វើការស៊ើបអង្កេត អាចត្រូវបានរកឃើញនៅក្នុងវិធានពាក់ព័ន្ធនឹងដីកាសម្រេចនានារបស់ អបជ។ វិធាន៧៨ ចែងថា៖

> រាល់សេចក្ដីសម្រេច ដែលមានសំលេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះ រួមទាំងមតិជំទាស់ផងត្រូវបោះពុម្ពផ្សាយទាំងស្រុង លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬការស៊ើបសួរ[31]។

28. ដោយការលើកឡើងពីវិធាន៧៨ ចៅក្រម អបជ បានថ្លែងនូវបទដ្ឋាន ដូចតទៅនេះ៖

> វិធាន ៧៨ នៃវិធានផ្ទៃក្នុងចែងថា រាល់សេចក្ដីសម្រេច ដែលមានសំឡេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្ដីសម្រេច ដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះ រួមទាំង មតិជំទាស់ផងត្រូវបោះពុម្ពផ្សាយទាំងស្រុង លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬការស៊ើបសួរ។
>
> ដូចនេះ ជាគោលការណ៍ វិធាន ៧៨ នៃវិធានផ្ទៃក្នុង និង មាត្រា ៤(ង) នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង តម្រូវឲ្យមានការ

[31] វិធាន៧៨ នៃវិធានផ្ទៃក្នុង។

ផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ អាស្រ័យហេតុនេះ ខ្លឹមសារនៃសេចក្តីសម្រេច ឬមតិយោបល់ ដែលមិនប៉ះពាល់ដល់ផលប្រយោជន៍នៃការស៊ើបសួរ មិនគួរមានការកោសលុបឡើយ[32]។

29. វិធាន៧៧ ពាក់ព័ន្ធនឹងនីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ និងពាក្យសុំទៅអង្គបុរេជំនុំជម្រះ។ កថាខណ្ឌ៦ នៃវិធានផ្ទៃក្នុង ឆ្លុះបញ្ចាំងពីចេតនានៃការប្រជុំពេញអង្គដើម្បីធានាដល់តម្លាភាពជាសាធារណៈចំពោះប្រភេទនៃដីកាសម្រេចជាក់លាក់ទាក់ទងក្នុងដីកាដំណោះស្រាយនេះ - កាលណាសំណុំរឿងមួយត្រូវបានបញ្ចប់ផ្អែកលើការបកស្រាយករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក៖

> តាមសំណើរបស់ចៅក្រមណាម្នាក់ ឬរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ **ជាពិសេសនៅពេលដែលសំណុំរឿងនោះអាចត្រូវបានបញ្ចប់ ដោយសេចក្តីសម្រេចរបស់ខ្លួន** ដូចជាពាក្យបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ**ពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ ឬមូលហេតុដែលនាំឱ្យរលត់បណ្តឹងអាជ្ញា** បើអង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ[33]។

30. សារៈសំខាន់នៃការចូលមើលជាសាធាថារណៈ ក៏បានឆ្លុះបញ្ចាំងផងដែរនៅក្នុង "គោលការណ៍សវនាការជាសាធារណៈ"[34] នៅដំណាក់កាលនៃការជំនុំជម្រះក្តី[35] និងដំណាក់កាលនៃការប្តឹងឧទ្ធរណ៍[36] និងលក្ខខណ្ឌតម្រូវដែលថាអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលធ្វើការប្រកាសសាលក្រម និងសាលដីការបស់ខ្លួន នៅក្នុងសវនាការជាសាធារណៈមួយ[37]។

---

[32] **D239/1/8** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*, មតិយោបល់របស់ចៅក្រមអន្តរជាតិ, ១ មីនា ២០១៦, កថាខណ្ឌ២-៤។

[33] វិធាន៧៧ នៃវិធានផ្ទៃក្នុង (សង្កត់ន័យបន្ថែមដោយ**អក្សរដិតក្រាស់**)។

[34] វិធាន២៩(៤)(ង) នៃវិធានផ្ទៃក្នុង។

[35] វិធាន៧៩(៦) នៃវិធានផ្ទៃក្នុង។

[36] វិធាន១០៩(១) នៃវិធានផ្ទៃក្នុង។

[37] វិធាន៧៩(៦)(ឃ) នៃវិធានផ្ទៃក្នុង។ វិធាន១០២ នៃវិធានផ្ទៃក្នុង។

31. សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង នៅ អ.វ.ត.ក ក៏បានបញ្ជាក់ផងដែរពីសារៈសំខាន់នៃតម្លាភាពនៅអ.វ.ត.ក ដោយកត់សម្គាល់ពី "តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរ្តិ៍ដំណែល"[38]។ ការចូលចិត្តទៅខាងការចូលមើលជាសាធារណៈ ក៏បានបញ្ជាក់ផងដែរដោយលក្ខខណ្ឌតម្រូវនៅក្នុងសេចក្តីណែនាំអនុវត្ត ដែលថាអង្គជំនុំជម្រះចុងក្រោយដែលបានប្តឹងដោយសំណុំរឿងមួយ ត្រូវតែពិនិត្យមើលឡើងវិញនូវឯកសារទាំងអស់ដែលនៅតែចាត់ថ្នាក់ជាសម្ងាត់ ឬសម្ងាត់បំផុត សម្រាប់ការចាត់ប្រភេទឡើងវិញ[39]។ នៅពេលដែលដំណើរការពិនិត្យមើលឡើងវិញនេះនៅក្នុងសំណុំរឿង០០១ អជតក បានសម្រេចថាជាគោលការណ៍ ឯកសារទាំងអស់ដែលបានមកពីកិច្ចស៊ើបសួរ ត្រូវធ្វើឡើងជាសាធារណៈ "ដូច្នេះត្រូវអនុញ្ញាតឲ្យសាធារណជនទូទៅមានលទ្ធភាពពេញលេញនៅក្នុងការពិនិត្យមើលឯកសារ និងពង្រីកឲ្យមានតម្លាភាពដល់កម្រិតអតិបរមា"[40]។

32. អជតក ក៏បានកត់សម្គាល់ផងដែរថា "តម្រូវការនៃតម្លាភាពដែលកើតចេញពីគោលការណ៍ជាសារវន្ត ដែលគ្រប់គ្រងលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាលើគោលបំណងរបស់តុលាការក្នុងការអប់រំ និងរក្សាកេរ្តិ៍តំណែល"[41] និងបានសង្កត់ធ្ងន់ថា ទាក់ទងនឹងតម្លាភាព

> ការចែកចាយឲ្យបានទូលំទូលាយ នូវសម្ភារពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ និងរាល់សេចក្តីសម្រេចរបស់ខ្លួនលើអង្គហេតុ និងអង្គច្បាប់ គឺស្របទៅនឹងអាណត្តិរបស់ អ.វ.ត.ក ដែលរួមមានទាំងការចូលរួមចំណែកនៅក្នុងការផ្សះផ្សាជាតិ និងការផ្តល់ឲ្យនូវឯកសារ ដើម្បីគាំទ្រដល់ការស្វែងរកការពិតខាងផ្នែកប្រវត្តិសាស្ត្រយូរ អង្វែងមកហើយ។ ការយល់ដឹងរបស់សាធារណជន និងការពិភាក្សាវែកញែកអំពីទំព័រ ប្រវត្តិ

[38] ចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង, អនុម័តលើកទី២, មាត្រា១.២។

[39] ចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង, អនុម័តលើកទី២, មាត្រា១២.២។

[40] សំណុំរឿង០០១-**F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំ ស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង, ២៦ កក្កដា ២០១២, កថាខណ្ឌ៦។

[41] សំណុំរឿង០០១-**F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំ ស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង, ២៦ កក្កដា ២០១២, កថាខណ្ឌ៥។

សាស្ត្រកម្ពុជាដ៏សោកនាដកម្មទាំងនេះ គឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែងដើម្បីស្វែងរកជ័យជំនះឲ្យប្រជាជនកម្ពុជា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការចែកចាយឲ្យទូលំទូលាយនូវសេចក្តីសម្រេចរបស់ខ្លួន អាចចូលរួមចំណែកនៅក្នុងគោលបំណងនៃការផ្សះផ្សាជាតិ តាមរយៈការជំរុញឲ្យមានកិច្ចពិភាក្សាលើអតីតកាលជាពិសេស និងជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំមួយ ដែលជាលទ្ធផលអាចកាត់បន្ថយនូវទស្សនៈនៃការមិនទទួលស្គាល់ការបំភ្លៃអង្គហេតុ និងភាពពិតដែលមានតែមួយផ្នែកនោះបាន[42]។

*ii. ច្បាប់អន្តរជាតិ និងការផ្តល់អនុសាសន៍ មានទំនោរទៅរកតម្លាភាព*

33. មាត្រា១៤ នៃសន្ធិសញ្ញា ICCPR តម្រូវឲ្យ "សាលក្រមណាក៏ដោយ ដែលបានចេញនៅក្នុងករណីព្រហ្មទណ្ឌ ឬក្នុងបណ្តឹងរដ្ឋប្បវេណី ត្រូវតែធ្វើឡើងជាសាធារណៈ លើកលែងតែកាលណាមានផលប្រយោជន៍បុគ្គលដែលជាអនីតិជន ឬបើមិនដូច្នោះទេតម្រូវឲ្យមានផ្សេងពីនេះ ឬ កិច្ចដំណើរការនីតិវិធីខ្វល់ខ្វាយពីជម្លោះញាតិសន្តានខាងម្តាយ ឬភាពជាអ្នកគ្រប់គ្រងលើកូនក្មេង"[43]។ គោលការណ៍នេះ អនុវត្តដោយស្មើភាពគ្នាចំពោះការដោះលែងឲ្យរួចខ្លួន ក៏ដូចជា ការកាត់ឲ្យជាប់ទោសដែរ។ ការផ្តល់អនុសាសន៍ជាផ្លូវការចំពោះសន្ធិសញ្ញា ICCPR បញ្ជាក់ថា គោការណ៍នៃការប្រកាសជាសាធារណៈនេះអនុវត្តសូម្បីតែកាលណាកិច្ចដំណើរការនីតិវិធី ដែលបាននាំឆ្ពោះទៅរកចំណុចនោះមិនត្រូវបានធ្វើឡើងជាសាធារណៈ៖ "សូម្បីតែនៅក្នុងករណីដែលសាធារណជនមិនត្រូវបានរាប់បញ្ចូលនៅក្នុងកិច្ចដំណើរការនីតិវិធី សាលក្រម រួមមាន ការរកឃើញសំខាន់ៗ ភស្តុតាង និង សម្អាងហេតុតាមផ្លូវច្បាប់ ត្រូវតែធ្វើឡើងជាសាធារណៈ"[44]។

---

[42] សំណុំរឿង០០១-**F28** សាលដីកា, ៣ កុម្ភៈ ២០១២, កថាខណ្ឌ៧០៨ (ការលើកខាងក្នុងត្រូវបានរំលង)។ *សូមអាន ផងដែរ* សំណុំរឿង០០១-F30/2 សេចក្តីសម្រេចលើគោលការណ៍ណែនាំ ស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង, ២៦ កក្កដា ២០១២, កថាខណ្ឌ៥ (ផ្នែកដែលបានលើកឡើង គឺដូចគ្នា)។

[43] កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, មាត្រា១៤។

[44] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប, អនុសាសន៍ទូទៅ លេខ៣២, CCPR/C/GC/32, ២៣ សីហា ២០០៧, កថាខណ្ឌ២៩។

34. លក្ខន្តិកៈ និងវិធាននៃតុលាការអន្តរជាតិ និងតុលាការដែលធ្វើឱ្យទៅជាអន្តរជាតិ ក៏បានបញ្ជាក់ផងដែរពីគោលនយោបាយដែលមានទំនោរទៅរកតម្លាភាព ដោយតម្រូវឱ្យកិច្ចដំណើរការនីតិវិធីសវនាការនោះប្រព្រឹត្តទៅជាសាធារណៈ[45] ហើយនិងសាលក្រមត្រូវបានចេញជាសាធារណៈ[46]។ តុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) ដែលដូចគ្នានឹង អ.វ.ត.ក ដែរ គឺជាតុលាការកូនកាត់ដែលមានមូលដ្ឋាននៅលើគំរូប្រព័ន្ធច្បាប់ស៊ីវិល បានតម្រូវថា "ការដាក់ឯកសារមុនសវនាការលើអង្គសេចក្តី កិច្ចដំណើរការនីតិវិធី និង ដីកាសម្រេចផ្សេងៗទៀត ត្រូវធ្វើឡើងជាសាធារណៈ"[47]។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃ STL បានថ្លែងថា វាជាការ "យកចិត្តទុកដាក់ និងសង្កត់ធ្ងន់លើភាពចាំបាច់សម្រាប់តម្លាភាព នៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខតុលាការនេះ"[48] និងបានកត់សម្គាល់ថា "ការដាក់ជូន និងសេចក្តីសម្រេចជាសម្ងាត់ - ទោះបីជាមានការចាំបាច់ពេលខ្លះក៏ដោយ - ដោយចរិកលក្ខណៈរបស់វាមានទំនាស់ទៅនឹងគោលនយោបាយបើកចំហរនេះ។ វាគួរត្រូវបានរក្សាទុកក្នុងកម្រិតអប្បបរមា និងអាចត្រូវបានធ្វើយុត្តិកម្មតែចំពោះសម្អាងហេតុពិសេសប៉ុណ្ណោះ ដែលអាចនឹងរាប់បញ្ចូលទាំងការការពារជនរងគ្រោះ និងសាក្សី និងការការពារនូវកិច្ចស៊ើបសួរដែលកំពុងបន្ត..."[49]។

35. ករណីយុត្តិសាស្ត្ររបស់តុលាការ *បណ្តោះអាសន្ន* ក៏បានបញ្ជាក់ពីការនិយមចូលចិត្តខ្លាំងផងដែរចំពោះតម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ។ ដូចដែលអង្គជំនុំជម្រះតុលាការ

---

45 តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, វិធាននៃកិច្ចដំណើរការនីតិវិធី និង ភស្តុតាង, វិធាន៧៨។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា, វិធាននៃកិច្ចដំណើរការនីតិវិធី និង ភស្តុតាង, វិធាន៧៨។ តុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន, វិធាននៃកិច្ចដំណើរការនីតិវិធី និង ភស្តុតាង, វិធាន៧៨។

46 លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា,មាត្រា២២(២)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, មាត្រា២៣(២)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន, មាត្រា១៨។ តុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន, វិធាននៃកិច្ចដំណើរការនីតិវិធី និង ភស្តុតាង, វិធាន៨៨(ក)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, វិធាននៃកិច្ចដំណើរការនីតិវិធី និង ភស្តុតាង, មាត្រា៩៨ស្ទួនពីរ(ក)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា, វិធាននៃកិច្ចដំណើរការនីតិវិធី និង ភស្តុតាង, មាត្រា៨៨(ក)។

47 តុលាការពិសេសសម្រាប់ប្រទេសលីបង់, វិធាននៃកិច្ចដំណើរការនីតិវិធី និង ភស្តុតាង, វិធាន៩៦។

48 *រដ្ឋអាជ្ញា ទល់នឹង Ayyash និងគូកន,* សំណៅកែតម្រូវស្តីពីដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះលើសំណើសុំអនុលោមតាមវិធាន៦៨(ឆ), ២៩ មីនា ២០១២, កថាខណ្ឌ១២។

49 *រដ្ឋអាជ្ញា ទល់នឹង Ayyash និងគូកន,* សំណៅកែតម្រូវស្តីពីដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះលើសំណើសុំអនុលោមតាមវិធាន៦៨(ឆ), ២៩ មីនា ២០១២, កថាខណ្ឌ១២។

ឧទ្ធរណ៍នៃ STL បានសង្កេតឃើញថា “អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានសម្រេចយ៉ាងជាប់លាប់ថា រាល់សេចក្តីសម្រេចទាំងអស់ និងដីកាសន្និដ្ឋានទាំងអស់ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះ ត្រូវតែជាសាធារណ: លើកលែងតែវាមានសម្អាងហេតុពិសេសសម្រាប់ការក្សាទុកជាសម្ងាត់”[50]។ អង្គជំនុំជម្រះសាលាដំបូងនៃ ICTY បានកត់សម្គាល់ថា ការបានចូលមើលជាសាធារណ: “បានផ្តល់នូវកិច្ចការពារប្រឆាំងនឹងសេចក្តីសម្រេចតាមទំនើងចិត្ត និងកសាងនូវទំនុកចិត្តតាមរយៈការអនុញ្ញាតឱ្យសាធារណជនបានមើលពីការគ្រប់គ្រងលើយុត្តិធម៌”[51]។ អង្គជំនុំជម្រះសាលាដំបូងទីពីរនៃ ICTY បានកត់សម្គាល់ថា ការបានចូលមើលជាសាធារណ:ទៅលើការគ្រប់គ្រងវិស័យយុត្តិធម៌គឺអាចតាមចិត្តចង់បាន ពីព្រោះ “តុលាការអន្តរជាតិមានមុខងារអប់រំមួយ និងការបោះពុម្ពផ្សាយនូវសកម្មភាពជួយក្នុងការសម្រេចបាននូវគោលបំណងនេះ”[52]។ ការពង្រឹងនូវអារម្មណ៍នេះ គឺចៅក្រមអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃ ICTR/ICTY បានសរសេរថា ជវនចិត្តនៃតុលាការអន្តរជាតិ (ឬដែលធ្វើឱ្យទៅជាអន្តរជាតិ)មួយចំនួន ដូចជា ការគាំទ្រឱ្យមានការផ្សះផ្សា និងការធ្វើឱ្យរុងរឿងឡើងវិញ ហើយនិងការរក្សានូវសន្តិភាពគឺ “អាចទៅរួចតែកាលណាកិច្ចដំណើរការនីតិវិធីរបស់តុលាការត្រូវបានមើលឃើញថាមានតម្លាភាព ត្រូវតាមល័ក្ខការយុត្តិធម៌អន្តរជាតិដែលបានទទួលស្គាល់”[53]។

36. អង្គជំនុំជម្រះនៃ ICTR បានថ្លែងយ៉ាងច្បាស់លាស់ថាពួកគេមាន “គោលនយោបាយនៃការដាក់សេចក្តីសម្រេចជាឯកសារសាធារណ: ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ជាប្រយោជន៍ដើម្បី

---

[50] *រដ្ឋអាជ្ញា ទល់នឹង Ayyash និងគូកន,* សំណៅកែតម្រូវស្តីពីដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះលើសំណើសុំអនុលោមតាមវិធាន៦៨(ឆ), ២៩ មីនា ២០១២, កថាខណ្ឌ១២, កំណត់សម្គាល់ជើងទំព័រទី៣៤ (សំណុំរឿងប្រមូល)។

[51] *រដ្ឋអាជ្ញា ទល់នឹង Zejnil Delalic និងគូកន,* សេចក្តីសម្រេចលើញត្តិរបស់អយ្យការស្នើសុំវិធានការការពារសាក្សីនានារបស់អយ្យការ ដែលមានរហស្សនាមពី “ខ” ដល់ “ឌ”, អង្គជំនុំជម្រះសាលាដំបូង, ២៨ មេសា ១៩៩៧, កថាខណ្ឌ៣៤។

[52] *រដ្ឋអាជ្ញា ទល់នឹង Tadic,* សេចក្តីសម្រេចលើញត្តិរបស់អយ្យការស្នើសុំវិធានការការពារជនរងគ្រោះ និងសាក្សី, អង្គជំនុំជម្រះសាលាដំបូង, ១០ សីហា ១៩៩៥, កថាខណ្ឌ៣២។

[53] *Jean Bosco Barayagwiza ទល់នឹង រដ្ឋអាជ្ញា,* សេចក្តីសម្រេចលើសំណើរបស់អយ្យការ សុំឱ្យពិនិត្យ ឬពិចារណាឡើងវិញ, មតិយោបល់ដោយឡែករបស់ចៅក្រម Shahabuddeen, ៣១ មីនា ២០០០, កថាខណ្ឌ៧១។

ឲ្យមានតម្លាភាពចំពោះសាធារណជនទូទៅ"[54] ហើយចៅក្រមម្នាក់នៃអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ បានកត់សម្គាល់ថា៖

> តុលាការទាំងពី គឺ ICTY និង ICTR បានរកឃើញថាពួកគាត់នៅកណ្ដាលបរិយាកាសរំជួលចិត្តយ៉ាងពិតប្រាកដ និងត្រូវបានទទួលខុសត្រូវដោយករណីយកិច្ចមួយក្នុងការរក្សាឯករាជ និងតម្លាភាព ដូចដែលបានរំពឹងដោយសហគមន៍អន្តរជាតិ គឺការបង្ការទុកនូវបទដ្ឋាននៃសិទ្ធិមនុស្សអន្តរជាតិ។ សហគមន៍អន្តរជាតិចាំបាច់ត្រូវប្រាកដថា យុត្តិធម៌គឺត្រូវបានបម្រើ ក៏ប៉ុន្តែថាវាកំពុងត្រូវបានបម្រើតាមរយៈការអនុវត្តវិធាន និងច្បាប់លក្ខន្តិកៈរបស់វា ដែលត្រូវបានអនុវត្តទៅតាមរបៀបមួយដែលជាប់លាប់ និងមិនលំអៀង[55]។

37. កិច្ចដំណើរការនីតិវិធីនៃវិធាន១១*ស្ទួន* នៅ ICTY ត្រូវបានប្រើប្រាស់ នៅក្រោយដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយត្រូវបានចេញ ដោយយោងទៅដល់សំណុំរឿងនៃយុត្តាធិការជាតិ នៅពេលណាដែលវាជាការគួរ ពីព្រោះថា ទម្ងន់នៃឧក្រិដ្ឋកម្មដែលតិចជាងនេះ ឬកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទមិនតម្រូវឲ្យមានកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ ICTY ខ្លួនឯងទេនោះ។ សេចក្តីសម្រេចទាំងនេះ គឺមានជាសាធារណៈ ដោយមានការកោសលុបដ៏តិចតួចកាលណាវាមានការខ្វល់ខ្វាយចំពោះសុវត្ថិភាពរបស់សាក្សី ឬជនសង្ស័យ[56]។

38. តុលាការ ICC តម្រូវថា ស្ថិតក្នុងការលើកលែងមានកម្រិត សំណុំរឿងទាំងមូលនៃរឿងក្តីនានាត្រូវអាចរកបានជាសាធារណៈ[57]។ មតិយោបល់ទៅនឹងលក្ខន្តិកៈក្រុងរ៉ូម បានកត់សម្គាល់អំពីសារ

---

[54] *រដ្ឋអាជ្ញា ទល់នឹង* Edouard Karemera *និងគូកន*, សេចក្តីសម្រេចលើញត្តិរបស់អយ្យការ សុំឲ្យទទួលយក*កំណត់ហេតុ* ទាក់ទងនឹងសាក្សីឈ្មោះ Gay, ២៣ សីហា ២០១០, កថាខណ្ឌ១។

[55] *Jean Bosco Barayagwiza ទល់នឹង រដ្ឋអាជ្ញា*, សេចក្តីសម្រេចលើសំណើរបស់អយ្យការ សុំឲ្យពិនិត្យ ឬពិចារណាឡើងវិញ, សេចក្តីប្រកាសរបស់ចៅក្រម Rafael Nieto-Navia, ៣១ មីនា ២០០០, កថាខណ្ឌ១៨។

[56] *សូមអាន, ឧទា., រដ្ឋអាជ្ញា ទល់នឹង Mitar Rašević និង Sava Todović*, សេក្តីសម្រេចលើការបញ្ជូនសំណុំរឿងក្រោមវិធាន១១*ស្ទួន* ដោយមានឧបសម្ពន្ធសម្ងាត់ I និង II, អង្គចៅក្រមបញ្ជូនសំណុំរឿង, ៨ កក្កដា ២០០៥, កថាខណ្ឌ២៣។ *សូមអាន ផងដែរ, រដ្ឋអាជ្ញា ទល់នឹង Gojko Janković*, សេក្តីសម្រេចលើការបញ្ជូនសំណុំរឿង ក្រោមវិធាន១១*ស្ទួន*, អង្គចៅក្រមបញ្ជូនសំណុំរឿង, ២២ កក្កដា ២០០៥។

[57] តុលាការព្រហ្មទណ្ឌអន្តរជាតិ, វិធានស្តីពីនីតិវិធីនិងភ័ស្តុតាង, វិធាន១៥។

សំខាន់នៃការចូលមើលបានជាសាធារណៈចំពោះ "ដំណើរការរបស់ស្ថាប័នសាធារណៈ និងអន្តរជាតិ"[58]។ ក្នុងការដោះស្រាយថាតើ ត្រូវចាត់ថ្នាក់ឡើងវិញថាជាសាធារណៈ ឬយ៉ាងណា ចំពោះឯកសារដែលត្រូវបានធ្វើឡើងដោយសម្ងាត់នៅដំណាក់កាលអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានសម្រេចជាឯកច្ឆ័ន្ទឲ្យធ្វើដូច្នេះ ត្រង់ចំណុចដែលថាមូលហេតុសម្រាប់ភាពសម្ងាត់មិនមានអត្ថិភាពតទៅទៀតនោះ[59]។ នៅក្នុងយោបល់ដាច់ដោយឡែកមួយ ចៅក្រមម្នាក់ក្នុងចំណោមចៅក្រមទាំងឡាយបានពន្យល់អំពីលក្ខណៈដាច់ខាតនៃធ្វើឯកសារទៅជាសាធារណៈ នៅពេលដែលតម្រូវការណាមួយសម្រាប់ការសម្ងាត់នោះបានអស់សុពលភាពហើយនោះ។ គាត់បានមានយោបល់ថា វិធានអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ "ផ្តល់ការបង្ហាញនីតិវិធីទៅកាន់កាតព្វកិច្ចរបស់អង្គជំនុំជម្រះ ដើម្បីធានាដល់ភាពបើកចំហរនៃដំណើរការតុលាការ។ កាតព្វកិច្ចនេះកើតឡើងនៅពេលដែល មូលហេតុនានសម្រាប់ការមិនដាក់បង្ហាញបានរលាយបាត់ទៅ"[60]។ គាត់បានពន្យល់ថា ពាក្យពេចន៍នៃវិធាននេះបានថ្លែងថា អង្គជំនុំជម្រះនេះ "អាច" បង្គាប់ឲ្យមានការដាក់បង្ហាញ

> ក្នុងបរិបទនេះមិននាំមកនូវឆន្ទានុសិទ្ធិនោះទេ ប៉ុន្តែផ្តល់ការសម្តែងឲ្យឃើញចំពោះកាតព្វកិច្ចត្រូវធ្វើអ្វីដែលតម្រូវដោយច្បាប់។ ការសួរសំណួរថាតើ ក្នុងពេលមិនមានមូលហេតុធ្វើយុត្តិកម្មលើការបន្តបិទបាំងការផ្សព្វផ្សាយកិច្ចដំណើរការនីតិវិធី ដែលតុលាការមានឆន្ទានុសិទ្ធិទុកឲ្យនៅដដែល ឬយ៉ាងណានោះ នាំឲ្យលក្ខណៈដាច់ខាតនៃអំណាចដើម្បីធ្វើឲ្យកិច្ចដំណើរការនីតិវិធីជាសាធារណៈមានអាទិភាព។ ការដែលមិនធ្វើដូច្នេះ នឹងជាការប្រាសចាកចេញពីកាតព្វកិច្ចផ្តល់យុត្តិធម៌ដោយចំហរ។ ការមិនដាក់បង្ហាញភ័ស្តុតាងផ្ទាល់មាត់ ឬភ័ស្តុតាងឯកសារ ដែលបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនោះ និងលាក់កំបាំងពីដំណើរការនានារបស់តុលាការក្នុងពេលមិនមានហេតុផលណា ដែលអាចបញ្ជាក់ភាពត្រឹមត្រូវនៃជម្រើសនោះបាន។ នៅក្នុងកាលៈទេសៈទាំងអស់នោះ ការប្រាសចាកចេញពីនិយាមនៃសវនាការជា

---

58 Antonio Cassese និងអ្នកផ្សេងទៀត, កែសម្រួ., *លក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ អនុសាសន៍*, រោងពុម្ព Oxford University, ២០០២, ទំព័រ១២៨១។

59 *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Joseph Kony និងគូកន.*, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើការបើកឯកសារ, ៤ កុម្ភៈ ២០០៨, កថាខណ្ឌ ៥។

60 *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Joseph Kony និងគូកន.*, សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍លើការបើកឯកសារ, យោបល់ដោយឡែករបស់ចៅក្រម Georchios M. Pikis, ៤ កុម្ភៈ ២០០៨, កថាខណ្ឌ៤។

សាធារណៈនេះ មិនអាចរកបានយុត្តិកម្មណាមួយឡើយ។ កាតព្វកិច្ចធ្វើឱ្យទៅជាសាធារណៈនូវអ្វីដែលលេចឡើងនៅក្នុងរយៈពេលនៃដំណើរការតុលាការ មិនបញ្ចប់នៅ ចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីតុលាការឡើយ ប៉ុន្តែនៅមានតទៅទៀតក្រោយពេលនោះ ដោយចងភ្ជាប់កាតព្វកិច្ចតុលាការឱ្យតាមដានព្រឹត្តិការណ៍នោះ និងឱ្យដកចេញការរារាំងចំពោះសាធារណភាព នៅពេលណាដែល និងនៅទីណាដែលមូលហេតុសម្រាប់ការមិនដាក់បង្ហាញកន្លងផុតទៅ។...ការធានាអំពីការផ្សព្វផ្សាយនៃដំណើរការតុលាការ គឺជាកាតព្វកិច្ចយូរអង្វែង ដែលចងភ្ជាប់កាតព្វកិច្ចតុលាការឱ្យវាស់ស្ទង់ព្រឹត្តិការណ៍ទាំងអស់[61]។

39. នៅតុលាការ ICC ការបញ្ជាក់អំពីការចោទប្រកាន់របស់អង្គបុរេជំនុំជម្រះ អនុលោមតាមមាត្រា ៦១ នៃលក្ខន្តិកៈទីក្រុងរ៉ូម បម្រើជាការបញ្ជូនរឿងទៅជំនុំជម្រះក្នុងវិធីដូចគ្នាទៅនឹងដីការដំណោះស្រាយដែលធ្វើនៅ អ.វ.ត.ក នេះដែរ[62]។ ការអនុវត្តន៍របស់តុលាការ ICC គឺត្រូវស្តាប់សវនាការសាក្សីនៅដំណាក់កាលបញ្ជាក់ជាសាធារណៈ (លើកលែងតែបញ្ហាសន្តិសុខតម្រូវឱ្យមានវិធានការការពារសាក្សី) និងត្រូវចេញដីកាសម្រេចលើការបញ្ជាក់អំពីការចោទប្រកាន់ជាសាធារណៈ ដោយមានការកោសលុបកម្រិតត្រឹមតែឈ្មោះសាក្សី និងជនរងគ្រោះដែលត្រូវការពារតែប៉ុណ្ណោះ។ ការណ៍នេះពិតដូចគ្នាក្នុងករណីដែលការចោទប្រកាន់មិនត្រូវបានបញ្ជាក់[63]។ ដូចដែលចៅក្រមម្នាក់នៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានកត់សម្គាល់ "សវនាការសាធារណៈដែលធានាដល់ភាពបើកចំហរនៃដំណើរការតុលាការ ត្រូវបានប្រមើលដោយលក្ខន្តិកៈទីក្រុងរ៉ូម នៅរាល់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងអស់ ដែលពាក់ព័ន្ធទៅនឹងការវិនិច្ឆ័យទាក់ទងនឹងការបញ្ជាក់អំពីការចោទប្រកាន់ ការជំនុំជម្រះជនជាប់ចោទ និងកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍"[64]។

---

[61] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Joseph Kony និងគូកន.,* សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍លើការបើកឯកសារ, យោបល់ដោយឡែករបស់ចៅក្រម Georchios M. Pikis, ៤ កុម្ភៈ ២០០៨, កថាខណ្ឌ៤ (យោងសំអាងខាងក្នុងត្រូវបានលុប)។

[62] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៦១។

[63] *សូមអាន ជាឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Bahar Idriss Abu Garda,* សេចក្តីសម្រេចស្តីពីការបញ្ជាក់ចំពោះបទចោទ, សំណៅកោសលុបជាសាធារណៈ, អង្គបុរេជំនុំជម្រះ, ៨ កុម្ភៈ ២០១០។ *រដ្ឋអាជ្ញា ទល់នឹង Callixte Mbarushimana,* សេចក្តីសម្រេចស្តីពីការបញ្ជាក់ចំពោះបទចោទ, សំណៅកោសលុបជាសាធារណៈ, អង្គបុរេជំនុំជម្រះ, ១៦ ធ្នូ ២០១១។

[64] *រដ្ឋអាជ្ញា ទល់នឹង Joseph Kony នឹងគូកន.,* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ស្តីពីការបើកបញ្ចេញឯកសារ, មតិដោយឡែករបស់ចៅក្រម Georchios M. Pikis, ៤ កុម្ភៈ ២០០៨, កថាខណ្ឌ ២។

40. មាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស តម្រូវឲ្យសាលក្រមប្រកាសជាសាធារណៈ។ អនុសញ្ញា ECtHR បានកត់សម្គាល់អំពីសារសំខាន់នៃការអនុញ្ញាតឲ្យ "ការត្រួតពិនិត្យមើលតុលាការដោយសាធារណជន"[65]។ វាក៏បានសង្កេតផងដែរថា ការចូលមើលជាសាធារណៈចំពោះកិច្ចដំណើរការនីតិវិធី គឺជា "វិធានសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រនានា ដែលទំនុកចិត្តលើតុលាការអាចត្រូវបានរក្សា"[66]។ អនុសញ្ញា ECtHR ក៏បានសម្រេចផងដែរថា៖

> សាធារណជន ត្រូវតែអាចយល់អំពីសាលក្រមដែលបានផ្ដល់ឲ្យ។ នេះគឺជាការការពារដ៏សំខាន់មួយប្រឆាំងនឹងការបំពាន។ ដូចដែលតុលាការនេះបានកត់សម្គាល់ជាញឹកញាប់ វិធាននៃច្បាប់ និងការជាសវាងការរំលោភអំណាចគឺជាគោលការណ៍ជាមូលដ្ឋានរបស់ [អនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស] [...] នៅក្នុងវិសាលភាពតុលាការ គោលការណ៍ទាំងនោះបម្រើដើម្បីលើកកម្ពស់ទំនុកចិត្តសាធារណៈ នៅក្នុងប្រព័ន្ធយុត្តិធម៌ប្រកបដោយតម្លាភាព និងសត្យានុភាព ដែលជាមូលដ្ឋានគ្រឹះមួយក្នុងចំណោមមូលដ្ឋានគ្រឹះនានារបស់សង្គមប្រជាធិបតេយ្យ[67]។

41. តម្លាភាពមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការជំនុំជម្រះព្រហ្មទណ្ឌអន្តរជាតិ និងដែលមានលក្ខណៈជាអន្តរជាតិ វាជួយកសាងទំនុកចិត្តនៅក្នុងស្ថាប័នតុលាការពិសេសទាំងអស់នេះ ខណៈដែលបម្រើផងដែរដល់គោលបំណងអន្តរយុត្តិធម៌របស់តុលាការ។ បន្ថែមលើយុត្តិធម៌ តុលាការព្រហ្មទណ្ឌអន្តរជាតិមានគោលបំណងធ្វើឲ្យជឿនលឿនដល់ "ការកសាងសន្តិភាព ការផ្សះផ្សារ ការបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ និងនិយាមវិញ្ញាតិភាពនិយម"[68]។ អតីតប្រធានចៅក្រមនៅតុលាការ ICTY ចៅក្រម Theodor Meron បានសរសេរថា៖

> តម្លាភាពមានសារៈសំខាន់ក្នុងការកសាងទំនុកចិត្តសាធារណៈ នៅក្នុងការដំណើរការតុលាការដ៏ត្រឹមត្រូវ ហើយបន្តិចម្ដងៗ ទំនុកចិត្តសាធារណៈមានសារៈសំខាន់ក្នុងការលើកកម្ពស់

[65] *រឿងក្ដី Ryakib Biryukov ទល់នឹង ប្រទេសរុស្ស៊ី*, សាលក្រម, ៧ កក្កដា ២០០៨, កថាខណ្ឌ ៤៥។

[66] *រឿងក្ដី Werner ទល់នឹង ប្រទេសអូទ្រីស*, សាលក្រម, ២៤ វិច្ឆិកា ១៩៩៧, កថាខណ្ឌ ៤៥។

[67] *រឿងក្ដី Taxquet ទល់នឹង ប្រទេសបែលស៊ិក*, សាលក្រម, ១៦ វិច្ឆិកា ២០១០, កថាខណ្ឌ ៩០។

[68] Sergey Vasiliev, *ការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌអន្តរជាតិ, ទ្រឹស្ដីធម្មនិយាមមួយ*, ២០១៤, ទំព័រ ៣៦៦។

ការយល់ដឹងដ៏ទូលំទូលាយអំពីការពារតុលាការ និងគាំទ្រការងាររបស់តុលាការ។ តម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ក៏បម្រើផងដែរជាការការពារដ៏សំខាន់មួយប្រឆាំងនឹងការបំពានតុលការនិងជួយធានាមិនត្រឹមតែភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងឯករាជភាព និងអព្យាក្រិត្តភាពរបស់ចៅក្រមជំនុំជម្រះ និងភាពអាចប្រមើលដឹងបាននៃសេចក្តីសម្រេចរបស់តលាការផងដែរ។ ហើយតម្លាភាពប្រហែលជាសំខាន់ជាពិសេសនៅក្នុងតុលាការព្រហ្មទណ្ឌដូចតុលាការទាំងនេះ ដែលបញ្ហានានាដែលជាចំណោទ រួមទាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទឡើងដ៏គួរឲ្យរន្ធត់នានា និងការសម្រេចលើពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ ទាំងអស់នេះធ្វើឲ្យវាកាន់តែមានសារសំខាន់ទៅទៀត ក្នុងការមានការប្រតិបត្តិតាមយ៉ាងច្បាស់លាស់ និងជាក់ស្តែងស្របតាមបទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិនៃដំណើរការនីតិវិធីដ៏ត្រឹមត្រូវ[69]។

42. សចសអ បានកត់សម្គាល់នៅក្នុងសំណេរផ្ទាល់របស់ខ្លួនថា៖ “អតីតប្រធាន ICTY លោក Antonio Cassese បានកត់សម្គាល់នៅក្នុងការថ្លែងរបស់គាត់ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងឆ្នាំ១៩៩៧ ថា ផ្នែកមួយនៃបេសកកម្មរបស់តុលាការនេះ គឺត្រូវបង្កើត “កំណត់ត្រាប្រវត្តិសាស្ត្រមួយ នូវអ្វីដែលបានកើតឡើងក្នុងពេលជម្លោះនៅទីនោះ ដោយទប់ស្កាត់ការបកស្រាយកំណត់ត្រាប្រវត្តិសាស្ត្រឡើងវិញ””[70]។ គោលបំណងទាំងឡាយនេះអាចសម្រេចបានដរាបណាសេចក្តីសម្រេចទាំងឡាយ ជាពិសេសសេចក្តីសម្រេចណាដែលមានសារសំខាន់ដូចដីកាដំណោះស្រាយ ត្រូវតែអាចរកបានជាសាធារណៈ។

## ខ. សចស បានខកខានមិនបានផ្តល់សម្អាងហេតុប្រកបដោយអង្គសេចក្តីសម្រាប់ការកោសលុបរបស់ខ្លួន

43. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សចស បានសម្រេចថា “គ្មានអ្វីដែល*តម្រូវឲ្យ*យើងចេញសំណៅជាសាធារណៈដោយមិនមានការកោសលុបនៃឯកសារណាមួយឡើយ”[71] (គូសបញ្ជាក់ក្នុងច្បាប់ដើម)។ ពួកគេកត់សម្គាល់ “ឆន្ទានុសិទ្ធិដ៏ទូលំទូលាយក្នុងការដោះស្រាយលើបញ្ហារក្សាការ

69 Theodor Meron, *ការកសាងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ: ទស្សនមួយពីអង្គចៅក្រម,* ២០១១, ទំព័រ ២៧៨។

70 Michael Bohlander, *យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ, ការវិភាគស៊ីជម្រៅមួយស្តីពីស្ថាប័ន និងនីតិវិធី,* ២០០៧, ទំព័រ ៧៧។

71 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៣។

សម្ងាត់នៅក្នុងអំឡុងពេលស៊ើបសួរ”[72] ថាពួកគេមាន និងអះអាងថាឆន្ទានុសិទ្ធិនេះលាតសន្ធឹងដល់ដីកាដំណោះស្រាយ ដែលមកនៅចុងបញ្ចប់នៃកិច្ចស៊ើបសួរ ពីព្រោះ “ការស៊ើបសួរបានបញ្ចប់ជាផ្លូវការតែពេលណាដែរ អ.ប.ជ បានសម្រេចលើបណ្ដឹងឧទ្ធរណ៍ណាមួយដែលជំទាស់នឹងដីកាដំណោះស្រាយតែប៉ុណ្ណោះ”[73]។ ពួកគេបានឯកភាពថា “វិធានផ្ទៃក្នុង ៥៦ មិនតម្រូវថា លទ្ធផលចុងក្រោយនៃការស៊ើបសួរត្រូវរក្សាការសម្ងាត់ឡើយ”[74] ប៉ុន្តែពួកគេថ្លែងបញ្ជាក់ថា ច្បាប់កម្ពុជា[75] និងការអនុវត្តន៍យុត្តិសាស្ត្រច្បាប់ស៊ីវិលមួយចំនួន[76] គាំទ្រសេចក្ដីសម្រេចរបស់ខ្លួនក្នុងការធ្វើការកោសលុប។

44. ការពិនិត្យលើវិសាលភាពដែលប្រភពនានាត្រូវបានយោងសម្អាងដោយ សចស គាំទ្រការរក្សាភាពសម្ងាត់នោះ គឺមានលក្ខណៈស្មុកស្មាញដោយអង្គហេតុដែលថា សចស មិនបានលើកឡើងឲ្យបានច្បាស់លាស់អំពីមូលហេតុនានាដែលពួកគេបានកោសលុប*ដីកាដំណោះស្រាយ (សម្អាងហេតុ)* នេះ។ ការពន្យល់តែមួយគត់ត្រូវបានរកឃើញនៅក្នុងសេចក្ដីប្រកាសព័ត៌មាន ដែល សចស បានផ្សព្វផ្សាយនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៧ នៅពេលដែលពួកគេបានចេញ*ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្ដី)*។ សេចក្ដីប្រកាសព័ត៌មានបានថ្លែងថា ការកោសលុបសម្អាងហេតុនៃការចោទប្រកាន់នានាទាំងនេះ ត្រូវបានធ្វើឡើង “ដោយសារថាដីកាដំណោះស្រាយមានលក្ខណៈជាការលើកលែងការចោទប្រកាន់”[77]។ ទោះជាយ៉ាងណា នៅក្នុងសេចក្ដីប្រកាសព័ត៌មាននេះ សចស មិនបានយោងទៅលើវិធានជាធរមាន គោលការណ៍ ឬ យុត្តិសាស្ត្រ ណាមួយនោះឡើយ ដើម្បីពន្យល់អំពីមូលហេតុដែលការលើកលែងការចោទប្រកាន់ មិនគួរត្រូវធ្វើជាសាធារណៈពេញលេញនោះ។

---

72 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៣។

73 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៣។

74 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៣។

75 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៦។

76 **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៦។

77 សេចក្ដីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេត, សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ២២ កុម្ភៈ ២០១៧។

45. នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ សចស ដែលបានប្រកាសអំពីការចេញ*ដីកាដំណោះស្រាយ (សម្អាងហេតុ)* សចស បានបញ្ជាក់បន្ថែមទៀតថា មូលហេតុដែលពួកគេជឿជាក់ថាការកោសលុបមានអង្គសេចក្តី គឺថាដោយសារតែការលើកលែងការចោទប្រកាន់នៃរឿងក្តីនេះដោយមូលហេតុកង្វះយុត្តាធិការ "អ៊ឹម ចែម នៅតែបន្តមានសិទ្ធិទទួលបានការសន្មត់ថាគ្មានទោស និងសិទ្ធឯកជនរបស់គាត់ ដែលបណ្តាលឱ្យមានការរឹតត្បិតនូវព័ត៌មានមួយចំនួន ដែលអាចផ្សព្វផ្សាយជាសាធារណៈ ហើយការរឹតត្បិតនេះមានលក្ខណៈតឹងរ៉ឹងជាងករណីដែលបញ្ជូនគាត់ទៅជំនុំជម្រះ។ សិទ្ធិទាំងនេះអនុវត្តបានមែន ប៉ុន្តែនៅតែអាចបើកផ្លូវឱ្យសាធារណជនទទួលបាននូវព័ត៌មានគ្រប់គ្រាន់អំពីការវិវត្តនៃកិច្ចដំណើរការនីតិវិធី"[78]។ សចស មិនបានពន្យល់បន្ថែមទៀតអំពីរបៀបដែលសច្ចាធារណ៍និរទោស ឬសិទ្ធិឯកជន "រឹតត្បិតនូវព័ត៌មានមួយចំនួន ដែលអាចផ្សព្វផ្សាយជាសាធារណៈ" នៅក្នុងរឿងក្តីនេះទេ។ សច្ចាធារណ៍និរទោសអនុវត្ត ថាតើដីកាដំណោះស្រាយបញ្ជូនបុគ្គលនោះទៅជំនុំជម្រះ ឬអត់។ សចស មិនបានផ្តល់ការពន្យល់ណាមួយចំពោះទស្សនៈរបស់ខ្លួនដែលថា មានតម្រូវការធំធេងចាំបាច់ត្រូវធ្វើឱ្យសាធារណជនទទួលបានព័ត៌មានក្នុងករណីបញ្ជូនខ្លួនទៅជំនុំជម្រះ ជាងក្នុងករណីច្រានចោលការចោទប្រកាន់។

46. វាមានតម្លៃកត់សម្គាល់ផងដែរថា គោលបំណងរបស់ សចស ទាក់ទងនឹងថិរវេលានៃចំណាក់ថ្នាក់រក្សាការសម្ងាត់នៃផ្នែកនានានៃ*ដីកាដំណោះស្រាយ (សម្អាងហេតុ)*មិនច្បាស់ទាំងស្រុងនោះទេ។ ជាពិសេស នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ខ្លួន ដែលអមជាមួយនឹង*ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី)* សចស បានថ្លែងថា សម្អាងហេតុទាក់ទងនឹងខ្លឹមសារនៃការចោទប្រកាន់នានា "ត្រូវរក្សាទុកជាការសម្ងាត់ រហូតដល់អង្គបុរេជំនុំជម្រះសម្រេចបដិសេធដីកាលើកលែងការចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះក្តី"[79]។ ការណ៍នេះបង្ហាញថា វាជាការរំពឹងទុករបស់ សចស ដែលថាសម្អាងហេតុលើការចោទប្រកាន់ទាំងនេះនឹងមិនត្រូវបានបង្ហាញជាសាធារណៈទេ លុះត្រាតែ អ៊ឹម ចែម បញ្ជូនទៅជំនុំជម្រះ។ ប៉ុន្តែ នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សចស ហាក់ដូចជាអះអាងថា ការរក្សាការសម្ងាត់មានអង្គសេចក្តីតាមវិធាន ៥៦ នៃវិធានផ្ទៃក្នុង ពីព្រោះតាមទស្សនៈរបស់ សចស "ដំណាក់ស៊ើបសួរបានបញ្ចប់ជាផ្លូវការតែពេលណាដែល អ.ប.ជ

---

[78] សេចក្តីប្រកាសព័ត៌មាន, សហចៅក្រមស៊ើបអង្កេតចេញសំអាងហេតុសម្រាប់ការលើកលែងការចោទប្រកាន់សំណុំរឿង ០០៤/០១, ១០ កក្កដា ២០១៧។

[79] សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេត, សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ២២ កុម្ភៈ ២០១៧។

បានសម្រេចលើបណ្ដឹងឧទ្ធរណ៍ណាមួយដែលជំទាស់ដីកាដំណោះស្រាយតែប៉ុណ្ណោះ"[80]។ ការណ៍នេះបានបង្ហាញថា ពួកគេនឹងមិនជំទាស់ទៅណឹងការចូលមើលជាសាធារណៈនោះទេចំពោះសម្អាងហេតុអំពីការចោទប្រកាន់នានា នៅពេលណាដែលបណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានបញ្ចប់នោះ ដោយមិនគិតអំពីលទ្ធលនោះឡើយ។ ក្នុងព្រឹត្តិការណ៍ណាក៏ដោយ វាច្បាស់ណាស់ថា សេចក្ដីសម្រេចណាមួយអំពីការរក្សាទុក ឬការដកចេញនូវការកោសលុបឥឡូវនេះ ស្ថិតក្នុងវង្វង់សមត្ថកិច្ចរបស់ អ.ប.ជ តែមួយគត់។

*i. ការយោងសម្អាងច្បាប់កម្ពុជាមិនគាំទ្រដល់ការកោសលុបឡើយ*

47. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សចស "យោងលើមាត្រា ៨៣(៤) និង ១២១(៥) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ បូករួមជាមួយនឹងមាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែលកំណត់ថា ការរំលោភលើការសម្ងាត់នៃការស៊ើបសួរគឺជាបទល្មើស"[81]។ ប៉ុន្តែ បញ្ហាលើបណ្ដឹងឧទ្ធរណ៍នេះ មិនមែនថាតើវាជាកំហុស ឬយ៉ាងណាក្នុងការរំលោភលើដីកាបង្គាប់រក្សាការសម្ងាត់ក្នុងអំឡុងពេលស៊ើបសួរនោះទេ - ច្បាស់ណាស់វាពិតជាមិនអាចទទួលយកបានឡើយចំពោះអ្នកណាម្នាក់ដែលធ្វើដូច្នេះ។ ផ្ទុយទៅវិញ បញ្ហានោះគឺ៖ ដោយសារតែវិធាន អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិល្មៀងទៅរកតម្លាភាព ក្រោយពេលបញ្ចប់ការស៊ើបសួរ ថាតើប្រភេទឯកសារអ្វី ឬព័ត៌មានណាគួរត្រូវបានចាត់ថ្នាក់ថាសម្ងាត់ និងត្រូវបដិសេធចំពោះសាធារណជន? បទប្បញ្ញត្តិដែលបានយោងសម្អាងទាំងនេះ មិនបាននិយាយអ្វីទាល់តែសោះអំពី ថាតើដីកាដំណោះស្រាយអាចត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឬយ៉ាងណា នៅពេលដែលការស៊ើបសួរបានបញ្ចប់នោះ។ មាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលត្រូវបានយោងសម្អាងដោយ សចស ចែងថា៖ "មិនមែនជាបទល្មើសទេក្នុងករណីដែលច្បាប់អនុញ្ញាត ឬតម្រូវឲ្យបង្ហាញអាថ៌កំបាំង"។ ចំពោះ អ.វ.ត.ក វិញ ច្បាប់នេះអនុញ្ញាតយ៉ាងច្បាស់ឲ្យអង្គជំនុំជម្រះពាក់ព័ន្ធផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានណា ដែលពួកគេជឿជាក់ថាសមរម្យ[82] និងក្នុងចំណោម "គោលការណ៍ជា

[80] **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៣។

[81] **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៦។

[82] *សូមមើល* វិធាន ៥៦(២) នៃវិធានផ្ទៃក្នុង។ សេចក្ដីណែនាំអនុវត្តស្ដីពីការចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង, វិសោធនកម្មលើកទី២, មាត្រា ៩.១។ សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, វិសោធនកម្មលើកទី៨, មាត្រា ៣.១២, ៣.១៤។

មូលដ្ឋាន” នៃវិធានផ្ទៃក្នុង មាត្រា ២១ ប្រគល់អាណត្តិឲ្យចៅក្រមទាំងអស់នៅ អ.វ.ត.ក ធ្វើការបកស្រាយច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត “ដើម្បីធានា ... តម្លាភាពនៃកិច្ចដំណើរការនីតិវិធី...”។

*ii. ការយោងសម្អាងក្រមច្បាប់ស៊ីវិលមិនគាំទ្រការកោសលុបឡើយ*

48. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សចស អនុវត្តតាមការយោងដោយសង្ខេបរបស់ខ្លួនទៅច្បាប់កម្ពុជា ដែលចែងអំពីការរក្សាការសម្ងាត់ក្នុងអំឡុងពេលស៊ើបសួរ ដោយមានការលើកឡើងថា “បទប្បញ្ញត្តិស្រដៀងគ្នាទាក់ទងនឹងការផ្សព្វផ្សាយជាសាធារណៈមុនពេលជំនុំជម្រះក្តី ក៏មានចែងផងដែរនៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិលប្រទេសផ្សេងទៀត ឧទាហរណ៍ដូចជា ប្រទេសអាល្លឺម៉ង់ ស្វីស និងបារាំង ជាដើម”[83]។ ក្រមច្បាប់ទាំងបីដែល សចស យោងសម្អាងមិនបង្ហាញពន្លឺណាមួយលើបញ្ហានានានៅក្នុងរឿងក្តីនេះទេ ដោយសារតែ៖ ១) ពួកវាដោះស្រាយការរក្សាការសម្ងាត់ក្នុងអំឡុងពេលស៊ើបសួរ មិនមែននៅពេលកិច្ចស៊ើបសួរត្រូវបានបញ្ចប់ហើយនោះទេ និង ២) ពួកវាទាក់ទងនឹងការដាក់បង្ហាញសម្ភារៈ **ដែលមិនត្រូវបានអនុញ្ញាត** ក្នុងអំឡុងពេលស៊ើបសួរ មិនមែនថាតើអង្គតុលាការគួរចាត់ថ្នាក់សេចក្តីសម្រេចលើកលែងការចោទប្រកាន់រឿងក្តីមួយថាជាការសម្ងាត់ ឬយ៉ាងណា ដែលនេះជាបញ្ហាតែមួយគត់នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

49. សចស យោងសម្អាងផ្នែកមួយនៃ ជំពូក ៣៥៣ឃ នៃក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ដែលចែងថា វាជាបទល្មើសក្នុងផ្សព្វផ្សាយជាសាធារណៈអំពី “ពាក្យពេចន៍ដើមពីផ្នែកខ្លះដែលសំខាន់ ឬផ្នែកទាំងអស់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬឯកសារផ្លូវការផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយ ជានីតិវិធីដែលត្រូវដាក់ទោសជាប្រាក់ពិន័យ ឬជានីតិវិធីដាក់ទោសវិន័យ មុនពេលដែលព័ត៌មានទាំងនោះបានលើកឡើងនៅក្នុងសវនាការសាធារណៈ **ឬមុនពេលដែលកិច្ចដំណើរការនីតិវិធីនោះបានបញ្ចប់**”[84]។ កត់សម្គាល់ថា បទប្បញ្ញត្តិនៃក្រមនេះចែងថា វាមិនមែនជាបទល្មើសទេក្នុងការបង្ហាញឯកសារពីកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅពេលដែល “កិច្ចដំណើរការនីតិវិធី

---

[83] **D309/2** ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៦។

[84] **D309/2** ដីកាសម្រេចដែលរងការជំទាស់, កំណត់សំគាល់ជើងទំព័រ ២០។ *សូមអានផងដែរ* ក្រមព្រហ្មទណ្ឌប្រទេសអាល្លឺម៉ង់ (សំណៅជាភាសាអង់គ្លេស ឆ្នាំ២០១០), វាក្យខណ្ឌ 353d, (សង្កត់ន័យដើម), អាចរកបានតាម https://ec.europa.eu/anti-trafficking/sites/antitrafficking/files/criminal_code_germany_en_1.pdf។

នោះបានបញ្ចប់” ដូច្នេះបទប្បញ្ញត្តិនេះពិតជាគាំទ្រថា ដីកាដំណោះស្រាយដែលបានចេញក្រោយការបញ្ចប់កិច្ចស៊ើបសួរគួរតែជាសាធារណៈ។

50. មាត្រា ២២៦-១៣ នៃក្រមព្រហ្មទណ្ឌសាធារណរដ្ឋបារាំង ចាត់ទុកថាជាការរំលោភបំពានព្រហ្មទណ្ឌក្នុងការដាក់បង្ហាញ “ព័ត៌មានសម្ងាត់ ដោយបុគ្គលដែលត្រូវបានប្រគល់ឱ្យនូវព័ត៌មានសម្ងាត់ ដោយសារតែមុខតំណែងរបស់គាត់ ឬវិជ្ជាជីវៈរបស់គាត់ ឬដោយសារតែមុខងារ ឬបេសកកម្មបណ្ដោះអាសន្ន”[85]។ ទោះជាយ៉ាងណា មាត្រាបន្ទាប់នៃក្រមព្រហ្មទណ្ឌបារាំង បង្ហាញចំណុចមួយថា នៅពេលដែលអង្គតុលាការមានសមត្ថកិច្ចអនុញ្ញាតឱ្យមានការផ្សព្វផ្សាយនោះ វា*ដោយស្វ័យប្រវត្តិ* មិនមែនជាការរំលោភបំពានទេ។ មាត្រា ២២៦-១៤ ចាប់ផ្តើមថា៖ “មាត្រា ២២៣-១៣ មិនអាចអនុវត្តបានចំពោះករណីនានាដែលច្បាប់កំណត់ ឬអនុញ្ញាតឱ្យដាក់បង្ហាញព័ត៌មានសម្ងាត់”។

51. ដូចគ្នានេះដែរ មាត្រា ២៩៣ នៃក្រមព្រហ្មទណ្ឌស្វីស ដែល សចស យោងសម្អាង គ្មានការពាក់ព័ន្ធទាល់តែសោះទៅនឹងបណ្ដឹងឧទ្ធរណ៍នេះ ចំពោះបញ្ហាថាតើការរកឃើញនៅក្នុងដីកាដំណោះស្រាយគួររក្សាជាការសម្ងាត់ ឬឱ្យសាធារណជនចូលមើលបាន។ មាត្រានេះពាក់ព័ន្ធតែទៅនឹងការដាក់បង្ហាញសម្ភារសម្ងាត់ដែលមិនត្រូវបានអនុញ្ញាតប៉ុណ្ណោះ៖ “ជនណាដែល**មិនមានការអនុញ្ញាត**ផ្សព្វផ្សាយព័ត៌មានពីសំណុំរឿង កិច្ចដំណើរការនីតិវិធី ឬការស៊ើបសួរផ្លូវការរបស់អាជ្ញាធរសាធារណៈ ដែលត្រូវបានប្រកាសថាជាការសម្ងាត់ដោយអាជ្ញាធរនោះ ស្របតាមអំណាចរបស់ខ្លួន ត្រូវទទួលពិន័យ”[86]។ អ្វីដែលពាក់ព័ន្ធនឹងបញ្ហាលើបណ្ដឹងឧទ្ធរណ៍នេះជាងនេះទៀតនោះគឺ សេចក្តីសម្រេចឆ្នាំ ២០១៦[87] របស់តុលាការសហព័ន្ធស្វីស ដែលបានសម្រេចថា ស្ថិតក្រោមយុត្តិសាស្ត្ររបស់ប្រទេសស្វីស សារព័ត៌មានផលប្រយោជន៍ស្របច្បាប់ក្នុងការចូលមើលសេចក្តីសម្រេចលើកលែងការចោទប្រកាន់ “ដោយសារតែមុខងារត្រួតពិនិត្យទូទៅដែលពួកគេមានជាធម្មតា”[88]។ សេចក្តីសម្រេចនេះ

---

[85] ក្រមព្រហ្មទណ្ឌប្រទេសបារាំង (សំណៅជាភាសាអង់គ្លេស ឆ្នាំ២០០៥), មាត្រា 226-13, អាចរកបានតាម http://www.legislationline.org/documents/section/criminal-codes/country/30។

[86] ក្រមព្រហ្មទណ្ឌប្រទេសស្វីស (សំណៅជាភាសាអង់គ្លេស ឆ្នាំ២០១៧), មាត្រា 293, (សង្កត់ន័យដើម), អាចរកបានតាម https://www.admin.ch/opc/en/classified-compilation/19370083/201707110000/311.0.pdf។

[87] *A. ទល់នឹង វិទ្យុ ទូរទស្សន៍ស្វីស*, Arret TF 1C_13/2016 ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦។

[88] *A. ទល់នឹង វិទ្យុ ទូរទស្សន៍ស្វីស*, Arret TF 1C_13/2016 ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦, កថាខណ្ឌ ៥.៤។ ការបកប្រែក្រៅផ្លូវការពីភាសាបារាំង “Selon la jurisprudence, les médias disposent en principe d'un intérêt suffisant à accéder à une décision de classement, en raison de la fonction de contrôle général qu'ils assument habituellement ... .”។

ទាក់ទងនឹងរឿងក្ដីមួយដែលទទួលបានការចាប់អារម្មណ៍ពីសាធារណជនយ៉ាងខ្លាំង គឺជនសង្ស័យបានធ្វើសេចក្ដីថ្លែងទៅកាន់សារព័ត៌មាន ហើយបទចោទប្រកាន់ព្រហ្មទណ្ឌនានាត្រូវបានលើកលែងដូចគ្នាទៅនឹងស្ថានភាព អ៊ឹម ចែម ដែរ។ តុលាកាស្វីស បានសម្រេចថា “ស្ថិតក្នុងកាលៈទេសៈទាំងនេះ វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សាធារណជនក្នុងការដឹងអំពីមូលហេតុដែលរឿងក្ដីព្រហ្មទណ្ឌមួយ ដែលមានផលប៉ះពាល់ខ្លះនោះ ជាចុងក្រោយបានបញ្ចប់ដោយមិនមានការជំនុំជម្រះ”[89]។

### *iii. សិទ្ធិរបស់ អ៊ឹម ចែម ក្នុងការទទួលបានសច្ចធារណ៍នៃនិរទោស និងឯកជនភាព មិនគាំទ្រដល់ការកោសលុបទេ*

52. ការអនុញ្ញាតឲ្យចូលមើលជាសាធារណៈចំពោះសម្អាងហេតុនៃការចោទប្រកាន់ជាសារធាតុនៅក្នុង *ដីកាដំណោះស្រាយ (សម្អាងហេតុ)* មិនបានសម្រុះសម្រួលដល់សិទ្ធិរបស់ អ៊ឹម ចែម ក្នុងការទទួលបានសច្ចធារណ៍នៃនិរទោសនោះទេ។ គាត់មានសិទ្ធិក្នុងការទទួលបានសច្ចធារណ៍នៃនិរទោស លើកលែងតែ និងរហូតទាល់តែ គាត់ត្រូវបានកាត់ឲ្យជាប់ទោស ហើយរឿងនោះគឺវាពិត សូម្បីតែគាត់ត្រូវបានកោះហៅ និងត្រូវបានបញ្ជូនឲ្យទៅជំនុំជម្រះក៏ដោយ[90]។ ដីកាដំណោះស្រាយដែលបានចេញដោយ សចស មិនមែនជាការកំណត់ពីពិរុទ្ធភាពនោះទេ គឺជាមុខងារមួយដែលអាងហេតុផលលើអង្គជំនុំជម្រះសាលាដំបូង[91]។ ពួកវាគ្រាន់តែជាការកំណត់ទាក់ទងនឹងបទចោទអ្វីខ្លះដែលបុគ្គលម្នាក់អាចត្រូវបានបញ្ជូនទៅជំនុំជម្រះ ដែលប្រើប្រាស់នូវបទដ្ឋានភស្តុតាងដែលតិចជាងបទដ្ឋាននៃ “ការហួសពីវិមតិសង្ស័យ” ដែលចាំបាច់សម្រាប់កាត់ឲ្យជាប់ទោស[92]។

---

89 *A. ទល់នឹង វិទ្យុ ទូរទស្សន៍ស្វីស*, Arret TF 1C_13/2016 of 18 avril 2016, para. 5.4. ការបកប្រែក្រៅផ្លូវការពីភាសាបារាំង “Dans ces circonstances, il importe manifestement au public de savoir pour quelles raisons une affaire pénale ayant eu un certain retentissement s'est finalement achevée sans procès.”។

90 *សូមអាន* ច្បាប់ អ.វ.ត.ក, មាត្រា៥៥ថ្មី (“ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ”)។ ICCPR, មាត្រា១៤(២)។ *សូមអានផងដែរ រដ្ឋអាជ្ញា ទល់នឹង* *Rasim Delić*, សេចក្ដីសម្រេចលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធី, ២៩ មិថុនា ២០១០, កថាខណ្ឌ១៤។

91 វិធាន៩៨ នៃវិធានផ្ទៃក្នុង។

92 វិធាន៦៧ នៃវិធានផ្ទៃក្នុង។ សំណុំរឿង០០២-**D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, កថាខណ្ឌ១៣២៣-១៣២៦។

53. យ៉ាងណាក៏ដោយ សច្ចធារណ៍នៃនិរទោសមិនតម្រូវឱ្យរាល់ភស្តុតាងទាំងអស់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលបានលើកឡើងចោទប្រកាន់របស់ចុងចោទ ត្រូវបានរក្សាទុកពីសាធារណជននោះទេ។ បើសិនរឿងនេះវាជាករណីមែននោះ សវនាការមួយមិនអាចកើតឡើងបានជាសាធារណៈនោះទេ ព្រោះថាជនជាប់ចោទមិនទាន់ត្រូវបានកាត់ឱ្យជាប់ទោស និងបានរីករាយជាមួយនឹងសច្ចធារណ៍នៃនិរទោសនៅក្នុងឱកាសនោះ។ សច្ចធារណ៍នៃភស្តុតាងក៏មិនបានរារាំងដល់ការចូលមើលជាសាធារណៈ ចំពោះដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ មុននឹងមានការចាប់ផ្តើមសវនាការដែរ[93]។ ពិតមែនហើយ ដូចដែល សចសអ បានពន្យល់នៅក្នុងសំណុំរឿង០០៣ ដូច្នេះថា សច្ចធារណ៍នៃនិរទោស មិនត្រូវបានប៉ះពាល់ដោយដីកាដំណោះស្រាយនោះទេ ទោះបីជាមាននរណាត្រូវបានបញ្ជូនទៅជំនុំជម្រះក៏ដោយ៖

> ការស៊ើបអង្កេតបែបនេះពុំប្រកាសអំពីពិរុទ្ធភាព ឬភាពគ្មានទោសឡើយ ហើយប្រសិនបើវានឹងចប់ដោយការចោទប្រកាន់ វាមិនមានន័យលើសពីការបញ្ចេញយោបល់របស់ សចស ដែលថាជនត្រូវចោទត្រូវឆ្លើយសំណុំរឿង *តាមការសន្និដ្ឋានបឋម* ពីព្រោះបទដ្ឋាននៃការចោទប្រកាន់គឺ *ពុំ* មែនជាបទដ្ឋាននៃ “ហួសពីវិមតិសង្ស័យ” ឬ “ការចោទប្រកាន់ទាន់ពេលវេលា” ឡើយ។ ភាពគ្មានទោសរបស់ មាស មុត នឹងត្រូវបានសន្មតក្នុងអំឡុងកិច្ចដំណើរការនីតិវិធីទាំងមូលរហូតដល់មានសាលក្រមស្ថាពរ[94]។ (អក្សរទ្រេតទាំងអស់ ជាឯកសារដើម)។

54. ដូចដែល សចសអ បានកត់សម្គាល់ពីមុននៅក្នុងសំណុំរឿង០០៣ ថា អ.វ.ត.ក មិនផ្តល់នូវសិទ្ធិដែលមានជាប់ជាមួយ ដើម្បីដកយកនូវព័ត៌មានពីសាធារណជននោះទេ រួមមាន ភស្តុតាងដាក់បន្ទុកក្នុងគោលបំណងដើម្បីការពារដល់កេរ្តិ៍ឈ្មោះរបស់ជនត្រូវចោទ៖

> អំណះអំណាងទាក់ទងសច្ចធារណ៍នៃនិរទោសគឺជាការខុសឆ្គង។តាមការពិត មាស មុត ប្តឹងធំពីផលប៉ះពាល់ទៅលើកេរ្តិ៍ឈ្មោះរបស់គាត់ និងសិទ្ធិឯកជនរបស់គាត់។ បណ្តឹងនេះគ្មានមូលដ្ឋាន។ នាពេលថ្មីៗ អ.ប.ជ បានសម្រេចក្នុងសំណុំរឿង០០៤ ថាវិធានផ្ទៃ ក្នុង

---

[93] សំណុំរឿង០០២-**D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០។

[94] សំណុំរឿង០០៣-**D100/32** ដីកាសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៣ ទៅក្នុងសំណុំរឿង០០២ (ឯកសារ D100/25 និង D100/29), ១៦ សីហា ២០១៦, កថាខណ្ឌ៣១។

២១ ពុំបានផ្តល់*សិទ្ធិ* ដែលមានជាប់មកជាមួយក្នុងការទទួលបានសុចរិតភាពនៃការអនុវត្ត កិច្ចស៊ើបអង្កេត កិច្ចស៊ើបអង្កេតដោយសម្ងាត់ ឬការការពារកិត្តិយសរបស់គាត់ឡើយ។ ...

... ការណ៍ដែលថាសិទ្ធិសច្ចធារណ៍នៃនិរទោស ពុំហាមឃាត់ការដាក់បង្ហាញព័ត៌មាន អំពី រួមទាំង ភស្តុតាងពីសំណុំរឿងមួយ ឬថែមទាំងចម្លើយនានាដែលបញ្ជាក់អះអាង អំពីអត្ថិភាពនៃការសង្ស័យសមហេតុផលអំពីពិរុទ្ធភាព ឬការព្យាករណ៍អំពីលទ្ធផលនៃការជំនុំជម្រះ ត្រូវបានបង្កើតឡើងក្នុងយុត្តិសាស្ត្រសិទ្ធិមនុស្សអន្តរជាតិ[95]។

55. យ៉ាងណាក៏ដោយ សូម្បីតែព្យសនកម្មទៅនឹងកេរ្តិ៍ឈ្មោះជាការខ្វល់ខ្វាយសុពលមួយក៏ដោយ ក្នុងគោលបំណងដើម្បីវាយតម្លៃព្យសនកម្មណាមួយចំពោះកេរ្តិ៍ឈ្មោះរបស់ អ៊ឹម ចែម ដែលថាការផ្សាយជាសាធារណៈនៃសម្អាងហេតុរបស់ សចស ពាក់ព័ន្ធនឹងការចោទប្រកាន់ជាសារធាតុដែលអាចនឹងកើតឡើងក៏ដោយ គេចាំបាច់ត្រូវតែពិចារណាពីឋានៈនៃកេរ្តិ៍ឈ្មោះរបស់បុគ្គល នៅពេលមុនការផ្សាយនោះ។ បើសិនជាសាធារណជនមិនបានដឹងថា អ៊ឹម ចែម ត្រូវប្រឈមនឹងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ វាអាចត្រូវជជែកគ្នាថា ការរកឃើញ*ដីកាដំណោះស្រាយ(សម្អាងហេតុ)* ដែលបញ្ជាក់ថាគាត់ **អាចនឹង** បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនប្រឆាំងនឹងមនុស្សជាតិ នឹងត្រូវបានធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់គាត់។ ក៏ប៉ុន្តែ ការពិនិត្យព័ត៌មានឡើងវិញមួយពាក់ព័ន្ធនឹង អ៊ឹម ចែម ដែលមានរួចជាស្រេចហើយ នៅក្នុងផេកជាសាធារណៈ រួមមាន វិបសាយ និងនៅក្នុងបណ្តាញព័ត៌មានរបស់ អ.វ.ត.ក ដែលអាចរកបានជាសាធារណៈ បញ្ជាក់ថា សាធារណជនបានដឹងឮយ៉ាងល្អប្រសើររួចជាស្រេចហើយអំពី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

56. *អ្នករាយការណ៍តុលាការ* នៃ អ.វ.ត.ក ដែលជាការបោះពុម្ពផ្សាយប្រចាំខែមួយបានផ្តល់នូវព័ត៌មានដល់សាធារណជនអំពីស្ថានភាពនៃសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក និងរឿងរ៉ាវដែលជាផលប្រយោជន៍ផ្សេងៗទៀត បានផ្តល់នូវហេតុការណ៍តុលាការថ្មីៗអំពីកិច្ចស៊ើបសួរ នៅក្នុងសំណុំរឿង ០០៤/១ នៅក្នុងលេខចេញផ្សាយនីមួយៗ ចាប់តាំងពី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ជាផ្លូវការ

[95] សំណុំរឿង០០៣-**D100/32** ដីកាសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៣ ទៅក្នុងសំណុំរឿង០០២ (ឯកសារ D100/25 និង D100/29), ១៦ សីហា ២០១៦, កថាខណ្ឌ៣០, ៣១។

នៅខែមីនា ឆ្នាំ២០១៥។ រូបថតរបស់ អ៊ឹម ចែម ត្រូវបានដាក់បង្ហាញជ្រងោនៅលើទំព័រវិបសាយរបស់ អ.វ.ត.ក[96] ហើយវិបសាយដែលបានទុកសម្រាប់រូបគាត់នោះ បានថ្លែងថា៖

អ៊ឹម ចែម ត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យចំពោះឧក្រិដ្ឋកម្ម៖

- មនុស្សឃាត ដែលជាការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលបានប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅមន្ទីរសន្តិសុខភ្នំទ្រយោង, និង

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅការដ្ឋានស្ពានស្រែង[97]។

57. សេចក្តីប្រកាសព័ត៌មានមួយពីចៅក្រម សចសអ Harmon ដែលប្រកាសអំពីការចោទប្រកាន់ អ៊ឹម ចែម *ដោយកំបាំងមុខ* ក៏បានរាយឈ្មោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនេះដែរ[98]។ លើសពីនេះ ការពិតដែលព័ត៌មានជាសាធារណៈនេះថា អ៊ឹម ចែម ត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងនេះ មានន័យថា សាធារណជនបានដឹងហើយថា សចសអ បានរកឃើញភស្តុតាងយ៉ាងច្បាស់ និងស៊ីសង្វាក់គ្នាទាក់ទងនឹងការចោទប្រកាន់នោះ[99]។ នៅលើគេហទំព័ររបស់ អ.វ.ត.ក ក៏មានសេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិផងដែរ ដែលសង្ខេបនូវដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន

---

[96] https://www.eccc.gov.kh/en។

[97] https://www.eccc.gov.kh/en/charged-person/im-chaem។

[98] សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង០០៤, ៣ មីនា ២០១៤, អាចរកបាននៅលើគេហទំព័រ: https://www.eccc.gov.kh/en/articles/international-co-investigating-judge-charges-im-chaem-absentia-case-004។

[99] វិធាន៥៥(៤) នៃវិធានផ្ទៃក្នុង។

នៅក្នុងសំណុំរឿង០០៤/១ ដូចដែលបានអនុញ្ញាតតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុង។ នៅក្នុងសេចក្ដីប្រកាសព័ត៌មានរបស់ខ្លួន ដែលអមដោយការចេញ*ដីកាដំណោះស្រាយ(សម្អាងហេតុ)* សចស បានធ្វើការកត់សំគាល់ថា "ការលើកលែងការចោទប្រកាន់ដោយសារកង្វះយុត្តាធិការបុគ្គល មិនស្មើនឹងសេចក្ដីថ្លែងការណ៍មួយដែលថា គ្មានបទល្មើសណាមួយត្រូវបានប្រព្រឹត្តដោយជនត្រូវចោទណាម្នាក់នោះទេ។ អាស្រ័យហេតុនេះ វាមិនត្រឹមត្រូវឡើយក្នុងសេណារីយ៉ោបែបនេះដែលថ្លែងដោយគ្មានគុណវុឌ្ឍិបន្ថែមថាជនត្រូវចោទ "បានដឹងច្បាស់" អំពីបទចោទទាំងនោះ[100]។ តាមពិត យើងអាចប្រកែកបានថា កិត្តិសព្ទរបស់ អ៊ឹម ចែម ត្រូវបានធ្វើឱ្យខូចជាងដោយសារការកោសលុប ពីព្រោះការកោសលុបនេះក៏រក្សាមិនឱ្យសាធារណជនបានដឹងអំពីទស្សនៈរបស់ សចស ទាក់ទងនឹងថាតើបទឧក្រិដ្ឋណាមួយ ដែលត្រូវបានចោទប្រកាន់ក្នុងសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ សពអ ទាក់ទងនឹងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន សចស មានអារម្មណ៍ថាមិនមានភ័ស្តុតាងគាំទ្រនោះ។

58. យ៉ាងណាមិញ មិនមែនមានតែ អ.វ.ត.ក ប៉ុណ្ណោះទេដែលបានចែកចាយព័ត៌មានសម្បូរបែបជាសាធារណៈអំពីការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម។ ប្រពន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ បានធ្វើសេចក្ដីរាយការណ៍យ៉ាងទូលំទូលាយលើករណីនេះ រួមទាំងព័ត៌មានអំពីបទចោទ និងទីតាំងឧក្រិដ្ឋកម្ម។ ការស្រាវជ្រាវមួយនៅលើ Google News ស្វែងរកឈ្មោះ អ៊ឹម ចែម ពេលនោះវាបានបញ្ចេញលទ្ធផលជាង២០០[101]។ ជាឧទាហរណ៍ អត្ថបទមួយស្ដីពី អ៊ឹម ចែម *នៅលើ New York Times* ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៧មក មានផ្ទុកនូវសម្រង់ពីសំណួរផ្សេងៗ ដែលគាត់បានឆ្លើយដល់អ្នកកាសែត រួមទាំងរូបថតខ្លួនគាត់មួយសន្លឹក និងកំណត់សំគាល់នានាដែលថា គាត់ត្រូវបានចោទពី "បទឧក្រិដកម្មប្រឆាំងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើឱ្យទៅជាទាសករណ៍" ដោយមានការពិភាក្សាអំពីភ័ស្តុតាងទាក់ទងនឹងបទចោទទាំងនោះផងដែរ[102]។

---

100 សេចក្ដីប្រកាសព័ត៌មាន, សហចៅក្រមស៊ើបអង្កេតចេញសំអាងហេតុសម្រាប់ការលើកលែងការចោទប្រកាន់សំណុំរឿង ០០៤/០១, ១០ កក្កដា ២០១៧។

101 ការស្រាវជ្រាវនេះស្ទើរតែផលិតបានតែចំណែកខ្លះនៃការផ្សព្វផ្សាយទាំងអស់តែប៉ុណ្ណោះ ដោយសារថាវាមិនចាប់យកអត្ថបទសារព័ត៌មានដែលមិនមាននៅលើវិបសាយ ឬមានតែជាភាសាខ្មែរ។

102 Julia Wallace, New York Times, *ជីវិតជនបទរបស់ជីដូនកម្ពុជាម្នាក់ដែលត្រូវបានចោទប្រកាន់ចំពោះការសម្លាប់រង្គាល, (The Bucolic Life of a Cambodian Grandmother Accused of Mass Killings)*, ២៤ កុម្ភៈ ២០១៧។

59. ការចុះផ្សាយយ៉ាងទូលំទូលាយរបស់សារព័ត៌មានដដែលនេះអំពីការស៊ើបអង្កេតប្រឆាំង អ៊ឹម ចែម ក៏បំរើដល់ការបដិសេធនៃភាពជំពាក់ជំពិនដែល សចស បានភ្ជាប់ថា សិទ្ធិឯកជនរបស់ អ៊ឹម ចែម នឹងទទួលរងផលប៉ះពាល់មិនល្អឡើយ តាមរយៈការបញ្ចេញសម្អាងហេតុពេញលេញទាក់ទងនឹងបទចោទជាសាធារណៈនោះ។ និយាយឲ្យងាយស្តាប់ ការផ្សព្វផ្សាយរបស់សារព័ត៌មានអំពីការពាក់ព័ន្ធរបស់ អ៊ឹម ចែម ដូចបានអះអាង អំពីបទល្មើសនានានៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ - ដែលជាញឹកញាប់តែមានកិច្ចសហការរបស់គាត់ - គឺមានភាពរីករាលដាលយ៉ាងខ្លាំង ធ្វើឲ្យបញ្ហាទាំងអស់នោះលែងជាបញ្ហា"ឯកជន"ទៀតហើយ ទោះបីជាវានៅតែជាឯកជនក៏ដោយ។ អ៊ឹម ចែម ធ្លាប់បាននិយាយដោយចំហរជាមួយ DC-Cam[103] និងអ្នកកាសែត[104] អំពីតួនាទីរបស់គាត់នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសេចក្តីថ្លែងការណ៍ទាំងអស់នោះ គាត់បានអះអាងទាក់ទងនឹងអំពើប្រព្រឹត្តរបស់គាត់នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ហើយដូចដែលបានពោលខាងលើ តាំងពីចេញ*ដីកាដំណោះស្រាយ(សម្អាងហេតុ)* រួចមក មេធាវីរបស់គាត់ផ្ទាល់បានធ្វើអត្ថាធិប្បាយជាសាធារណៈស្តីពី*ដីកាដំណោះស្រាយ(សម្អាងហេតុ)* ដោយបានបង្ហាញចរិកនៃការរកឃើញទាំងនេះថា ជាការរួចផុតពីការចោទប្រកាន់។

60. សចស មិនបានផ្តល់និយមន័យ ឬប្រភពនៃសិទ្ធិឯកជន ដែលពួកគាត់បានលើកយោងនោះទេ ប៉ុន្តែ សពអ សន្មត់ថា ពួកគេកំពុងតែលើកយោងទៅរកសិទ្ធិដូចបានកំណត់អត្តសញ្ញាណនៅក្នុងមាត្រា ១៧(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលចែងថា: "គ្មានជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកតាមទំនើងចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ"[105]។ ប៉ុន្តែ គេគួរតែច្បាស់ថា ការបញ្ចេញជាសាធារណៈនូវឯកសារតុលាការណាមួយ បើសិនជាមានការពាក់ព័ន្ធទៅនឹងឯកជនភាព គេមិនធ្វើដូច្នេះតាម "ទំនើងចិត្ត ឬខុសច្បាប់" ឡើយ ដូច្នេះវាមិនរំលោភសិទ្ធិនោះទេ។ ដូចអង្គជំនុំជម្រះនៃតុលាការ ICC បានសម្រេចគឺថា សិទ្ធិឯកជន "មិនអាចត្រូវបានគេមើលឃើញថា ជាសិទ្ធិដាច់ខាតឡើយ ឲ្យតែលិខិតុបករណ៍ដដែលទាំងនេះ ផ្តល់នូវសញ្ញាបង្ហាញអ្វីមួយដែលអាចនឹងត្រូវបានពិចារណាថាជា "ការជ្រៀតជ្រែក

---

[103] **D1.3.28.4** កំណត់ហេតុ DC-Cam របស់ អ៊ឹម ចែម, ៤ មីនា ២០០៧។

[104] សុក ខេមរា, VOA, ជនសង្ស័យទីពីរនៃសាលាក្តី ច្រានចោលការចោទប្រកាន់របស់អយ្យការ, ១១ សីហា ២០១១។

[105] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៧(១)។

ដោយខុសច្បាប់ទៅលើសិទ្ធិឯកជនជាមូលដ្ឋាន"[106]។ តាមពិត អបជ ធ្លាប់បានលើកពីចំណុចដូចគ្នានេះនៅពេលខ្លួនត្រូវដោះស្រាយពីបញ្ហាសិទ្ធិទាក់ទងនឹងកេរ្តិ៍ឈ្មោះ និងឯកជនភាពនៃមាត្រា១៧នេះ ក្នុងបរិបទនៃការដាក់បង្ហាញឯកសារ និងបានរកឃើញថាវាមិនមែនជាការរំលោភឡើយ៖

> អបជ រកឃើញ... ថា ពាក្យពេចន៍នៅក្នុងមាត្រា ១៧ នៃកតិកាសញ្ញា ICCPR ចែងលើកឡើងថា មាត្រានេះអនុញ្ញាតឲ្យមានការជ្រៀតជ្រែកទៅក្នុងឯកជនភាព ដរាបណាពុំធ្វើឡើង "តាមទំនើងចិត្ត" ឬ "ដោយខុសច្បាប់"។ ពាក្យថា "ដោយខុសច្បាប់" មានន័យថា គ្មានការជ្រៀតជ្រែកអាចធ្វើឡើងនោះទេ លើកលែងតែនៅក្នុងករណីនានាដែលចែងកំណត់ទុកជាមុនដោយច្បាប់។ វាក្យសព្ទ"ការជ្រៀតជ្រែកតាមទំនើងចិត្ត" ក៏អាចគ្របដណ្តប់លើការជ្រៀតជ្រែកដែលអនុញ្ញាតតាមច្បាប់ ហើយទស្សនទាននៃ "ទំនើងចិត្ត" មានចេតនាធានាថា សូម្បីការជ្រៀតជ្រែកដែលចែងអនុញ្ញាតដោយច្បាប់ គួរមានលក្ខណៈសមហេតុផលនៅក្នុងកាលៈទេសៈពិសេសនានា។ ចំណុចទីមួយ អង្គបុរេជំនុំជម្រះសូមរំលឹកថា ច្បាប់ជាធរមានពុំផ្តល់សិទ្ធិឲ្យជនត្រូវចោទមាន "សិទ្ធិជាប់មកជាមួយ" ក្នុងការទទួលបានការការពារកេរ្តិ៍ឈ្មោះនោះទេ។... ចំណុចទីពីរ អង្គបុរេជំនុំជម្រះកត់សំគាល់ថា ដីកាសម្រេចដែលត្រូវបានជំទាស់ ត្រូវបានចេញដោយស្ថាប័នតុលាការមានសមត្ថកិច្ចផ្អែកតាមច្បាប់ តាមរយៈដំណើរការតទល់ចំពោះមុខ និងត្រូវបានសម្រេចយ៉ាងសមហេតុផលក្នុងគោលបំណងស្របច្បាប់មួយ គឺក្នុងកិច្ចសហការដើម្បីបំពេញបេសកកម្មស្វែងរកការពិតដោយស្ថាប័នតុលាការមួយផ្សេងនៅ អ.វ.ត.ក។ ដូច្នេះ ដីកាសម្រេចនេះពុំត្រូវបានចេញតាមទំនើងចិត្តឡើយ[107]។

61. ចំណុចដូចគ្នា គឺមានពិតមែននៅទីនេះ។ *ដីកាដំណោះស្រាយ(សម្លាងហេតុ)* ត្រូវបានផលិតឡើងដោយស្ថាប័នតុលាការមានសមត្ថកិច្ចមួយ ផ្អែកតាមច្បាប់ តាមរយៈដំណើរការតទល់ចំពោះមុខ ហើយត្រូវបានសម្រេចអនុលោមតាមគោលបំណងស្របច្បាប់មួយ គឺក្នុងកិច្ចសហការដើម្បីបំពេញ

---

[106] *រដ្ឋអាជ្ញា ទល់នឹង Lubanga*, សេចក្តីសម្រេចលើការបញ្ជាក់អំពីបទចោទ, ២៩ មករា ២០០៧, កថាខណ្ឌ ៧៥។

[107] សំណុំរឿង០០៣-**D100/32/1/7** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29, ១៥ កុម្ភៈ ២០១៧, កថាខណ្ឌ ១៩ (សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ)។

បេសកកម្មស្វែងរកការពិតរបស់ អ.វ.ត.ក។ ដូច្នេះ ដីកាសម្រេចនេះពុំត្រូវបានចេញដោយខុសច្បាប់ ឬតាមទំនើងចិត្តឡើយ ហើយវាមិនរំលោភឯកជនភាពនោះទេ។

62. ប៉ុន្តែ អ្វីដែលកាន់តែរឹងមាំជាងនេះទៀតនោះ គឺគេមើលឃើញថា សិទ្ធិឯកជនរបស់ អ៊ឹម ចែម មិនទទួលរងការប៉ះពាល់**អ្វីទាំងអស់** តាមរយៈសម្អាងហេតុទាក់ទងនឹងបទចោទជាសារវ័ន្តទាំងនេះ។ អធិប្បាយទាក់ទងនឹងមាត្រា ១៧ បង្ហាញថា សិទ្ធិចំពោះឯកជនភាពគ្របដណ្តប់លើបញ្ហាដូចជាការប្រាស្រ័យទំនាក់ទំនងផ្ទាល់ខ្លួន ផ្ទះសម្បែងរបស់ជននោះ និងរាងកាយរបស់គាត់[108]។ គ្មានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលមានផ្ទុកកំណត់ហេតុដែលបានផ្តល់ដោយសាក្សីដោយស្ម័គ្រចិត្ត ទាក់ទងនឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេ មិនថាជាកំណត់ហេតុនិយាយពីឈ្មោះ អ៊ឹម ចែម ឬក៏គ្មានការសន្និដ្ឋានដោយ សចស នៅលើកំណត់ហេតុនោះទេ គឺសុទ្ធតែជាបញ្ហាដែលមិនត្រូវបានការពារដោយសិទ្ធិចំពោះឯកជនភាពរបស់ អ៊ឹម ចែម ឡើយ។

## គ. សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ

*63.* តាមជម្រើសផ្សេងទៅនឹងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ សពអ សូមស្នើឱ្យ អបជ ប្រើប្រាស់អំណាចរបស់ខ្លួន ក្នុងនាមជាអង្គជំនុំជម្រះដែលកំពុងកាន់សំណុំរឿង០០៤/១ ដើម្បីធ្វើចំណាត់ថ្នាក់ឡើងវិញលើសំណៅបច្ចុប្បន្ននៃ*ដីកាដំណោះស្រាយ(សម្អាងហេតុ)* ដែលដាក់ថា សម្ងាត់ ទៅជាសាធារណៈវិញ ដោយអនុលោមតាមមាត្រា ៩.១ នៃ សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទនិងការគ្រប់គ្រង ឬបង្កើតសំណៅសាធារណថ្មីមួយ ដោយអនុលោមតាមមាត្រា៩.២ ដោយកោសលុបតែសាក្សីណាដែលទទួលបានការការពារប៉ុណ្ណោះ[109] ប្រសិនជាមាន។ មាត្រា៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ក៏ផ្តល់ការអនុញ្ញាតឱ្យ អបជ នូវអំណាចក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញផងដែរៈ“តម្រូវតាមផលប្រយោជន៍យុត្តិធម៌ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលគ្រប់គ្រងសំណុំរឿង អាចដាក់ចំណាត់ប្រភេទឯកសារជាថ្មី ក្នុង

---

[108] អត្ថាធិប្បាយទូទៅ លេខ ១៦ របស់ CCPR: មាត្រា ១៧ (សិទ្ធិឯកជនភាព), ៨ មេសា ១៩៨៨, កថាខណ្ឌ៨។ *សូមអានផងដែរ* Rikke Frank Joergensen, *តើច្បាប់សិទ្ធិមនុស្សអាចមួលបង្កាច់ការឃ្លាំមើលរបស់មហាជនបានដែរឬទេ? (Can human rights law bend mass surveillance?)*, Internet Pol'y Rev., ២៧ កុម្ភៈ ២០១៤។

[109] វិធាន ២៩(៣) នៃវិធានផ្ទៃក្នុង។

សំណុំរឿង"[110]។ សពអ សន្និដ្ឋានថា សម្រាប់មូលហេតុដូចបានជម្រាបជូនខាងលើ ការធ្វើចំណាត់ថ្នាក់ឡើងវិញ គឺអាចធ្វើទៅបាននៅក្នុងផលប្រយោជន៍យុត្តិធម៌។

64. ជាការបន្ថែម ដោយផ្អែកលើមូលដ្ឋានដដែលនេះ សពអ ក៏សូមស្នើឲ្យ អបជ ធ្វើចំណាត់ថ្នាក់ឡើងវិញទៅជាសាធារណៈ ចំពោះដីកាសម្រេចដែលរងការជំទាស់ផងដែរ និងដាក់ចំណាត់ថ្នាក់បណ្តឹងឧទ្ធរណ៍នេះ (ព្រមទាំងចម្លើយតបណាមួយ ដែលមានការកោសលុបសមស្របចំពោះសាក្សី) ជាសាធារណៈ។ ពុំមានការពាក់ព័ន្ធទៅនឹងសាក្សី ឬភ័ស្តុតាងពីកិច្ចស៊ើបសួរ នៅក្នុងឯកសារទាំងនេះទេ ហើយក៏គ្មានមូលហេតុមិនឲ្យសាធារណជនចូលពិនិត្យមើលការជជែកផ្លូវច្បាប់នេះ ស្តីពីព្រំដែនកំណត់ទៅលើតម្លាភាព ធៀបនឹងភាពសម្ងាត់ នៅ អ.វ.ត.ក នេះឡើយ។

## V. សេចក្តីសន្និដ្ឋាន

65. អាស្រ័យដោយអាជ្ញាបញ្ញាផ្លូវច្បាប់ និងគោលនយោបាយដ៏ខ្លាំងក្លា ដែលមានទំនោរទៅរកតម្លាភាពនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក និងដោយសារគ្មានមូលហេតុដែលមានលក្ខណៈអន្ទងណាមួយដើម្បីរក្សាការកោសលុប សពអ សន្និដ្ឋានថា *ដីកាដំណោះស្រាយ(សម្លាងហេតុ)* ពេញលេញគួរត្រូវបានបញ្ចេញជាសាធារណៈ។

## VI. ដំណោះស្រាយដែលស្នើឡើង

66. អាស្រ័យមូលដ្ឋានដូចបានជម្រាបជូនខាងលើ សពអ សូមស្នើឲ្យអង្គជំនុំជម្រះនេះ ៖

ក. ដាក់ចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ ចំពោះដីកាសម្រេចដែលរងការជំទាស់ និង

ខ. កែប្រែដីកាសម្រេចដែលរងការជំទាស់ និងបញ្ចេញ *ដីកាដំណោះស្រាយ(សម្លាងហេតុ)* ជាសាធារណៈ ដោយមានការកោសលុបតែចំណុចចាំបាច់ សម្រាប់ការការពារសាក្សី អនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ៕

[110] សេចក្តីណែនាំអនុវត្តស្តីការដាក់ឯកសារ, វិសោធនកម្មលើកទី៨, មាត្រា ៣.១៤។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |